# និទ្ទាលកសូត្រ



ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ដល់បរិស័ទ

ផ្សាយចេញពីវត្តអង្គពណ្ណភាយណ៍ ភូមិប្រជុំអង្គ
ឃុំដើមកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា អាត្មាភាព
សាមណេរ មហារាជ យឿន តារា

ព.ស.២៥៥៧ គ.ស.២០១៤

# សិង្គាលកសូត្រ

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

សាមណេរ **មនោរថ យ៉ូន តារា**

ព.ស.២៥៥៧ គ.ស.២០១៤

ឈ្មោះសៀវភៅ: **សិង្គាលកសូត្រ**

ប្រមូលរៀបរៀងដោយ: សាមណេរ មនោរថ **យ៉ូន តារា**

**ជួយវាយកុំព្យូទ័រនិងអានដោយ :**

ភិក្ខុ **ថន ចាន់វណ្ណី**

សាមណេរ **ឈាម ឧសភា**

សាមណេរ **ជឿន ដា**

បញ្ញាសីលវា **កែវ រិទ្ធ**

ឧបាសក **ម៉ែន ចំរើន**

**ផ្ទៀងផ្ទាត់ដោយ :**

ព្រះអង្គគ្រូ **ខាន់ ខេន**

ភិក្ខុ **ថន ចាន់វណ្ណី**

យុវតី **ប៊ូ ចន្ទវតី**

យុវតី **ខន សុខនាង**

យុវតី **សុភា ម៉ារីណា**

លោកគ្រូ **ឌីម សុខជា**

លោកគ្រូ **ទ៉េត សំណាង**

**ជំនួយការបោះពុម្ពដោយ:**

ឧបាសក **ស្វាយ ហៃ** លោកអាចារ្យ **ម៉ម ម៉េ**

ឧបាសក **យ៉ាន សារិនយ៉ា** ឧបាសក **ម៉ែន ចំរើន**

**កាលបរិច្ឆេទ**: ព.ស.២៥៥៧ គ.ស.២០១៣

**ស្ថានទីធ្វើ** : **វត្តអង្គពណ្ណរាយណ៍** ភូមិប្រជុំអង្គ ឃុំជើងកែប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

**ធម្មទានដោយ**: ពុទ្ធបរិស័ទទូទៅ

# មាតិកា

មាតិកា..........I
ពាក្យប្រារព្ធ..........II
សេចក្តីចែកចំណែកបណ្យ..........V
សម្មោទនីយកថា..........VI
សិង្គាលកសូត្រ..........១
ឧបក្កិលេស៤ យ៉ាង..........១៧
ពោលអំពីអបាយមុខ ៦យ៉ាង..........៣១
បុគ្គលមិនមែនជាមិត្តមាន ៤ពួក..........៧០
មិត្ត ៤ពួកមានសន្តានល្អ..........៧៨
ទិសទាំង ៦ពោលអំពីទិសខាងត្បូង..........១១០
គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី៣..........១១៩
ទិសទាំង ៦ពោលអំពីទិសខាងជើង..........១២៣
គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី ៤..........១២៥
ទិសទាំង ៦ និយាយអំពីទិសខាងលើ..........១៣៨
សិង្គាលកមាណមដល់នូវត្រៃសរណគមន៍..........១៤៨
កំណាព្យញៀន..........១៥១
កំណាព្យអបាយមុខ..........១៥៣
កំណាព្យការសេពគប់..........១៥៥
ឈ្មោះសប្បុរសជនចូលរួមបោះពុម្ពសៀវភៅ..........១៥៨

# ពាក្យប្រារព្ធ

សៀវភៅ "សិង្គាលកសូត្រ" នេះ បានកើតជាសៀវភៅដែលរៀបរៀងដោយខ្ញុំព្រះករុណាអាត្មាភាព ក៏ដោយសារតែលោកម្ចាស់**ថនចាន់ វណ្ណឌី** លោកឲ្យយល់បល់ ថាធ្វើសៀវភៅសិង្គាលកសូត្រនេះ ព្រោះថា ជាប់ទាក់ទងជាមួយនឹងការគ្រប់គ្រងផ្ទះផង ហើយខ្ញុំក៏ចង់ធ្វើសៀវភៅជាប់ទាក់ទងជា មួយនឹងការគ្រប់គ្រងផ្ទះផងដែរនោះ ក៏បាន សម្រេចចិត្តដកស្រង់ពីគម្ពីរព្រះត្រៃបិដកនិងអដ្ឋកថាយកមកធ្វើជាសៀវភៅនេះឡើង ហើយ ។ ម្យ៉ាងទៀតសោតសៀវភៅដែលមានឈ្មោះថាសិង្គាលកសូត្រនេះ មានអ្នក ប្រាជ្ញទាំងឡាយបានធ្វើហើយ ប៉ុន្តែមិនធ្វើ ដូចនេះទេ គឺដកតែសេចក្តីសំខាន់ៗប៉ុណ្ណោះ ឥឡូវនេះខ្ញុំបានដកឲ្យអស់សេចក្តី គឺបិដកមួយវង់ជង្គាប់អដ្ឋកថា ពន្យល់បិដកមួយវង់ជង្គាប់ផងដែរ ហើយខ្ញុំក៏មិនបានដកមតិខ្លួនឯងមកបញ្ចូលដែរ ហើយក៏មិនបាន ដកអំពី សៀវភៅ

ផ្សេងៗ មានសារត្ថទីបនីដីកា ដែល ពន្យល់អដ្ឋកថា ជាដើមនោះដែរ ព្រោះថា ខ្ញុំក៏ ខ្វះសៀវភៅស្រាវជ្រាវ យកមកដាក់នោះផងទៀត ម្ល៉ោះហើយក៏បានប្រមូល ធ្វើតែប៉ុណ្ណឹង ។ ហើយខ្ញុំក៏អរគុណដែរចំពោះលោក ម្ចាស់ **ខាន់ ខេន** ជាព្រះគ្រូចៅអធិការវត្តអង្គពណ្ណារា-យណ៍ ដែលបានអនុញ្ញាតឲ្យទីកន្លែងធ្វើ សៀវភៅនេះ ដល់ខ្ញុំ ហើយក៏សូមថ្លែងអំណរ អរព្រះគុណចំពោះ សព្រហ្មចារីដែលជួយ វាយអក្សរ និងយុវសិស្សមាន កញ្ញា**វតី**ជាដើម ជួយខ្ទះខ្មែងពិនិត្យអក្សរសាស្ត្រា ។ ហើយ ប្រសិនបើមានការមិន គួរយ៉ាងណាសូមអ្នក ប្រាជ្ញទាំងឡាយ អភ័យទោសដល់រូបខ្ញុំផង។

ថ្ងៃ អាទិត្យ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ បញ្ចស័កព.ស.២៥៥៧

សាមណេរ **មនោរថ យ៉ូន តារា**

# សេចក្តីចែកចំណែកបុណ្យ

ដោយតេជានុភាព នៃវិរិយភាពដ៏ មោះមុតស្រួច ស្រាល់ទាំងក្នុងវ័យសិក្សា ២៥៥៥ រហូតមក ដែល បានពុះពារឧបសគ្គ តូចធំ ញ៉ាំងសមិទ្ធិតូចធំមានសំ-ណេរសៀវភៅនេះជាដើម ប្រតិស្ឋានទុកក្នុងព្រះពុទ្ធ-សាសនា និងប្រទេសជាតិនេះ ខ្ញុំសូមប្រគេន ថ្វាយ និងចែកជូននូវបុណ្យកុសលដែលកើត ឡើងអំពីការ បរិវត្តសៀវភៅជាដើមនេះ

-ដល់សម្តេចព្រះសង្ឃរាជទាំង២ គណៈ ព្រះរាជា-គណៈ ព្រះមន្ត្រីសង្ឃ ព្រះគ្រូ មេគណខេត្ត ព្រះគ្រូអ-នុគណស្រុក ព្រះគ្រូ ចៅអធិការវត្ត ព្រះវិនយាចារ្យ ព្រះធម្មាចារ្យ ព្រះឧទ្ទេសាចារ្យ គ្រប់លំដាប់ថ្នាក់គ្រប់ សម័យ

-ដល់សម្តេចព្រះ មហាក្សត្រខ្មែរព្រម ទាំងព្រះរាជ វង្សគ្រប់សម័យ

-ដល់មន្ត្រីអ្នកដឹកនាំប្រទេសជាតិ គឺ នាយករដ្ឋម-ន្ត្រី រដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ចៅ ហ្វាយខេត្ត អភិបាល-ស្រុក មេឃុំ មេភូមិ មេក្រុម នគរបាល ទាហាន យោ-ធា ប្រជារាស្ត្រ អ្នករៀន អ្នកអាន អ្នកឮ អ្នកដឹង គ្រប់លំដាប់ថ្នាក់

សូមឲ្យអ្នកទាំងអស់គ្នាត្រេចអរបុញ្ញរាសីនេះ ហើយ សូមកុំឲ្យមានទុក្ខ ភ័យ រោគគ្រប់ពេលទៅហោង...

សាមណេរ **មនោរថ យ៉ុន តារា**

# សម្ភោទនីយកថា

ខ្ញុំព្រះករុណា សូមកោតសរសើរនូវវិរិយភាពយ៉ាងវិសេសវិសាលរបស់ **សាមណេរ មនោរថ យ៉ូន តារា** ដែលបានព្យាយាមប្រមូលរៀបរៀងនូវកូនសៀវភៅនេះ ។

ខ្ញុំព្រះករុណា មានចិត្តរំភើបយ៉ាងខ្លាំង រកអ្វីមកប្រៀបពុំបានចំពោះការងារយ៉ាងលំបាក ហើយកម្រនឹងធ្វើបាននេះ ។ ម្យ៉ាងទៀត **សាមណេរ មនោរថ យ៉ូន តារា** បានប្រមូលរៀបរៀងសៀវភៅនេះ មានសារៈសំខាន់ដល់ពុទ្ធបរិស័ទដែលជាអ្នកគ្រប់គ្រងផ្ទះប្រាថ្នានូវមង្គល គឺសេចក្តីសុខចម្រើន ត្រូវតែសិក្សានូវក្នុងសៀវភៅនេះ ដើម្បីឲ្យដឹងអំពីការរស់នៅប្រចាំថ្ងៃ ឬឲ្យដឹងពីតួនាទីរវៀងមនុស្សម្នាក់ៗដែលត្រូវមានធម៌ជាសារៈ ។ អាស្រ័យហេតុនេះ ខ្ញុំព្រះករុណា សូមកោតសរសើរចំពោះស្នាដៃ និងការតាំងចិត្តយ៉ាងមុះ

មុតក្នុងការរៀបរៀង និងចងក្រងសៀវភៅនេះឲ្យបាន សម្រេចជាស្ថាពរ ហើយបោះពុម្ពផ្សាយជាសម្បត្តិ របស់វត្តអង្គពណ្ណរាយណ៍ ។

សូមស្នាដៃដ៏ពិសិដ្ឋនេះសម្រេចជាឥដ្ឋមនុញ្ញផល ដល់ពុទ្ធបរិស័ទគ្រប់ព្រះអង្គគ្រប់គ្នាហើយសម្រេចនូវ ពុទ្ធិចិត្តដូចសេចក្តីប្រាថ្នា ។ ម្យ៉ាងទៀត សូមអនុមោ-ទនាកុសលចេតនារបស់ពុទ្ធបរស័ទ ដែលមានសទ្ធា បានចូលរួមបោះពុម្ពសៀវភៅ "សិង្គាលកសូត្រ" នេះ ផ្សព្វផ្សាយជាធម្មទាន ។ សូមសត្វលោកទាំងឡាយ បានប្រកបដោយក្តីសុខគ្រប់ប្រការជានិច្ចនិរន្តរ៍ ។

វត្តអង្គពណ្ណរាយណ៍ថ្ងៃទី២០ខែ មេសាឆ្នាំ២០១៤

ចៅអធិការ



ភិក្ខុខេមការោ ខាន់ ខេន

# សិង្គាលកសូត្រ

( សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ
បិដកខ្មែរលេខ១៩ ទំព័រ៦៧ និង
អដ្ឋកថាខ្មែរ ភាគ១៩ ឈ្មោះសុមង្គលវិលាសិនី ទំព័រ ៥៨ )

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង កូនគហបតីឈ្មោះ សិង្គាលកៈ[១] ក្រោកឡើងអំពីព្រឹកមានសំពត់ស្លៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពី

---

[១] ហៅថា សិគាលកៈ ក៏មាន ដូចគ្នានិងពាក្យថា មហឹសៈ និង មហិសៈ សិរីសបៈ និងសិរិសបៈជាដើម ឃើញថាហៅបានដូចគ្នាទាំងពីរយ៉ាង ។

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

ក្រុងរាជគ្រឹះ ប្រណម្យអញ្ជលី ថ្វាយបង្គំទិស ទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិស ខាងលើ ។

ពាក្យថា **វេឡុវន** ក្នុងបទថា ក្នុងព្រះវិហារ វេឡុវ័ន ជាកន្លែងដែលព្រះរាជទានចំណី ដល់សត្វកង្ហែន ជាឈ្មោះរបស់ឧទ្យាននោះ ។ បានឮថាឧទ្យាននោះ បានឡោមព័ទ្ធ ដោយឫស្សី ប្រកបដោយស៊ុមទ្វារ និងប៉ម ដោយកំពែងខ្ពស់ ១៨ហត្ថ មានពន្លឺខៀវ ជាទីគួររីករាយ ដោយហេតុនោះ លោកទើប ហៅថា វេឡុវ័ន មួយទៀត ជនទាំងឡាយ បានឲ្យចំណីដល់កង្ហែនក្នុងសួនវេឡុវ័ននេះ

ដោយហេតុនោះទើបហៅថា កលន្ទកនិវាប ដែលជាទីព្រះរាជទានចំណីដល់សត្វកង្ហែន ។

មានរឿងដំណាលថា ក្នុងកាលមុន ព្រះ-រាជាមួយអង្គស្តេចប្រពាតសួន ក្នុងទីនោះ សោយទឹក សោមៈ[២]ដរាបដល់ទ្រង់ស្រវឹង ផ្ទំលក់ក្នុងពេលថ្ងៃ ។ សូម្បីជនបរិវាររបស់ព្រះអង្គគិតគ្នាថា ព្រះរាជាផ្ទំលក់ហើយ ពួកយើងនាំគ្នាទៅរកផ្កាឈើ និងផ្លែឈើជាដើម ទើបចៀសចេញទៅពីទីនោះៗ ។ គ្រានោះ

---

២

ឈ្មោះវល្លិមួយប្រភេទមានមើមស្រដៀងនិងមើមស្លែសម្រាប់ស្ងោរយកទឹកប្រើជាថ្នាំត្រជាក់ ។

ពស់វែក ព្រោះបានក្លិនសុរា ទើបលូនចេញចាករន្ធឈើមួយដើម មកចំពោះព្រះភ័ក្ត្រព្រះរាជា ។ រុក្ខទេវតា ឃើញពស់នោះគិតថា យើងនឹងឲ្យជីវិតដល់ព្រះរាជាដូច្នេះ ទើបក្លែងភេទជាសត្វកង្កែន ធ្វើសំឡេងជិតព្រះកាណ៌[៣] ។ ព្រះរាជាទ្រង់ភ្ញាក់ ពស់វែកក៏លូនចៀសចេញទៅ ។ ព្រះរាជាទតឃើញកង្កែននោះ ទ្រង់ ព្រះតម្រិះថា កង្កែននេះឲ្យជីវិតយើង ទើបត្រាស់បង្គាប់ឲ្យចាត់រកចំណីមកតាំងទុកក្នុងទីនោះ ត្រាស់បង្គាប់ឲ្យប្រកាស ឲ្យអភ័យដល់សត្វកង្កែនទាំងឡាយ ។ ព្រោះដូច្នោះ តាំងពីនោះមក ទីនោះទើប

---

[៣] ស្លឹកត្រចៀកស្ដេច

ឈ្មោះថា ជាទីព្រះរាជទានចំណីដល់សត្វកង្ហែន ។ មួយទៀត បទថា **កលន្ទកា**នេះ ជាឈ្មោះរបស់កង្ហែន ។ បទថា **ក៏ដោយសម័យនោះឯង** សេចក្តីថា ដោយសម័យដែលព្រះមានព្រះភាគទ្រង់ធ្វើក្រុងរាជគ្រឹះឲ្យជាគោចរគ្រាមហើយ ប្រថាប់នៅក្នុងព្រះ-វិហារ វេឡុវ័នដែលជាទីព្រះរាជទានចំណីដល់សត្វកង្ហែន ។ បទថា **សិង្គាលកោ គហ-បតិ បុត្តោ** ជាឈ្មោះរបស់គហបតីបុត្រនោះ ។ បទថា **បុត្ររបស់គហបតី** គឺគហបតីបុត្រ ។ បានឮថា បិតារបស់គហបតីបុត្រនោះ ជាគហបតីមហាសាល ។ ក៏គហបតីនោះ មានទ្រព្យរក្សាទុកក្នុងផ្ទះ៤០កោដិ ។ គហបតី

នោះ មានការជឿមុតមាំក្នុងព្រះមានព្រះភា-
គជាឧបាសកសម្រេចសោតាបន្ន ។ សូម្បី
ភរិយារបស់គេ ក៏សម្រេចសោតាបន្នដូចគ្នា
។ តែបុត្ររបស់គេមិនមានសទ្ធា មិនជ្រះថ្លា
។ គ្រានោះ មាតានិងបិតា រមែងប្រៀនប្រ-
ដៅបុត្រនោះរឿយៗ យ៉ាងនេះថា នែ៎!កូន
កូនចូរចូលទៅគាល់ព្រះសាស្តា ចូលទៅរក
ព្រះធម្មសេនាបតីសារីបុត្រ ព្រះមហាមោគ្គ-
ល្លាន ព្រះមហាកស្សបះ ព្រះមហាសាវក
៨០ ។ បុត្រនោះពោលយ៉ាងនេះថា ការ
ចូលទៅរកសមណៈទាំងឡាយរបស់ពុក
និងម៉ែ រមែងមិនមានដល់ខ្ញុំ ព្រោះការចូល
ទៅរកសមណៈទាំងឡាយ ក៏ត្រូវសំពះ

កាលឱនចុះសំពះខ្នងក៏ឈឺ ជង្គង់ក៏ក្រិនថាំ បាច់ត្រូវអង្គុយលើផែនដី កាលអង្គុយលើផែនដីនោះ សំពត់ក៏នឹងប្រឡាក់ និងចាស់ចាប់ផ្ដើមតាំងពីវេលាអង្គុយជិត រមែងមានការសន្ទនា កាលមានការសន្ទនា រមែងកើតសេចក្ដីស្និទ្ធស្នាល តអំពីនោះរមែងត្រូវនិមន្តហើយថ្វាយចីវរ និងបិណ្ឌបាតជាដើម បើដូច្នោះ ប្រយោជន៍រមែងសាបសូន្យការចូលទៅរកពួកសមណៈរបស់ពុកនិងម៉ែ រមែងមិនមានដល់ខ្ញុំដូច្នេះ ។ មាតាបិតាសូម្បីទូន្មានបុត្ររបស់គេរហូតអស់ជីវិតដោ-យប្រការដូច្នេះ ក៏មិនអាចនឹងនាំគេទៅកាន់សាសនាបាន ។ តមកបិតារបស់គេដេកលើ

ត្រៃសរណៈ គិតថាគួរនឹងឲ្យឱវាទដល់បុត្ររបស់យើងហើយគិតទៀតថា យើងនឹងឲ្យឱវាទដល់បុត្រយ៉ាងនេះថា នែ៎ កូនចូរកូនថ្វាយបង្គំទិសទាំងឡាយ គេមិនដឹងអត្ថន័យទើបថ្វាយបង្គំទិសទាំងឡាយ លំដាប់នោះព្រះសាស្តាឬព្រះសាវ័កទាំងឡាយឃើញគេហើយ ទើបសួរថា អ្នកធ្វើអ្វី គេក៏ពោលថាបិតារបស់ខ្ញុំទូន្មានទុកថា កូនចូរធ្វើការនមស្ការទិសទាំងឡាយលំដាប់នោះ ព្រះសាស្តាឬព្រះសាវ័កទាំងឡាយនឹងសម្តែងធម៌ដល់គេថា បិតារបស់អ្នកមិនឲ្យអ្នកនមស្ការទិសទាំងឡាយនោះ តែអ្នកនមស្ការទិសទាំងនេះ គេដឹងគុណក្នុងព្រះពុទ្ធសាសនា

ហើយនិងធ្វើបុណ្យ ដូច្នេះ ។ លំដាប់នោះ គហបតីឲ្យគេហៅបុត្រមក ហើយពោលថា នែ៎កូន កូនគួរក្រោកពីព្រឹកព្រលឹម ហើយ នមស្ការទិសទាំងឡាយដូច្នេះ ។ ធម្មតា ពាក្យរបស់បិតា ដែលដេកលើគ្រែមរណៈ រមែងជាពាក្យដែលបុត្រគប្បីរលឹកដល់រហូត អស់ជីវិត ។ ព្រោះដូច្នោះ គហបតីបុត្រនោះ កាលរលឹកដល់ពាក្យរបស់បិតា ទើបធ្វើ យ៉ាងនោះ ។ ព្រោះដូច្នោះ លោកទើប ពោលថា គហបតីបុត្រ ក្រោកឡើងពីព្រឹក ព្រលឹម ចេញចាកក្រុងរាជគ្រឹះជាដើម ។

បទថា **បុថុ ទិសា គឺ ទិសច្រើន** សេចក្តីថា ឥឡូវនេះ គហបតីបុត្រ កាលនឹងសម្តែង

ដល់ទិសទាំងឡាយនេះ ទើបពោលពាក្យជា
អាទិ៍ថាទិសខាងកើត ។

លំដាប់នោះឯង ព្រះមានព្រះភាគ ស្ដេច
ទ្រង់ស្បង់និងបាត្រចីវរក្នុងបុព្វណ្ហសម័យ
ហើយស្ដេចចូរទៅកាន់ក្រុងរាជគ្រឹះ ដើម្បី
បិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទត
ឃើញសិង្គាលកគហបតីបុត្រក្រោកឡើងអំ-
ពីព្រឹក មានសំពត់ស្លៀកដណ្ដប់ទទឹក និង
សក់ទទឹកចេញពីក្រុងរាជគ្រឹះ កំពុងផ្គង
អញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺ
ទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង
ខាងក្រោម និងទិសខាងលើ លុះទ្រង់ឃើញ
ហើយ ទើបទ្រង់ត្រាស់សួរសិង្គាលកគហប-

គីបុត្រដូច្នេះថា នៃគហបតីបុត្រ ហេតុអ្វី ទើបអ្នកក្រោកអំពីព្រឹកមានសំពត់ស្លៀកដ-ណ្តប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជ-គ្រឹះ កំពុងផ្គងអញ្ជលី ថ្វាយបង្គំទិសទាំង-ឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ។ សិង្គាលកគហបតីបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណភាព បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃបា អ្នកត្រូវតែថ្វាយ បង្គំទិស-ទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ ធ្វើសក្ការៈគោរពរាប់អានបូជា នូវពាក្យរបស់បិតា បានជាក្រោកឡើងអំពីព្រឹកមាន

សំពត់ស្លៀកដណ្តប់ទទឹក នឹងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហបតីបុត្រ ក្នុងវិន័យរបស់ព្រះអរិយគេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះទេ ។ សិង្គាលកគហបតីបុត្រក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើនចំណែកក្នុងអរិយវិន័យគេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន បើក្នុងវិន័យរបស់ព្រះអរិយគេគប្បីថ្វាយបង្គំចំពោះទិសទាំង៦ យ៉ាងណា សូមព្រះមាន-

ព្រះភាគទ្រង់សម្ដែងធម៌ដល់ខ្ញុំព្រះអង្គ ដូច្នោះចុះ ។

បទថា **ព្រះមានព្រះភាគ ស្ដេចចូលទៅហើយ** សេចក្ដីថា ព្រះមានព្រះភាគស្ដេចមិនទាន់ចូលទៅ ព្រោះព្រះអង្គទ្រង់ត្រិះរិះថា តថាគតនិងចូលទៅ ហើយស្ដេចចេញទៅសូម្បីប្រព្រឹត្តទៅនៅក្នុងចន្លោះផ្លូវ ទើបត្រាស់យ៉ាងនេះ ។ បទថា **ព្រះមានព្រះភាគបានទតព្រះនេត្រឃើញហើយដែរ** សេចក្ដីថាមិនបានទតព្រះនេត្រឃើញតែមួយដង ។ ព្រះមានព្រះភាគទ្រង់ត្រួតមើលលោកដោយពុទ្ធចក្ខុ សូម្បីក្នុងពេលព្រឹកព្រលឹមទតឃើញសិង្គាលកគហបតីបុត្រនោះ កំពុង

នមស្ការទិសទាំងឡាយ ទ្រង់ត្រិះរិះថា ថ្ងៃនេះតថាគតនឹងសម្តែងសិង្គាលកសូត្រ ដែលជា វិន័យរបស់គ្រហស្ថ ដល់សិង្គាលកគហបតីបុត្រ ពាក្យនោះទើបមានផលដល់មហាជន តថាគតគួរទៅក្នុងទីនោះដូច្នេះ ។ ព្រោះដូច្នោះ ព្រះអង្គស្តេចយាងពីព្រឹកព្រលឹមស្តេចចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត មួយទៀត កាលស្តេចចូលទៅបានទតព្រះនេត្រឃើញសិង្គាលកគហបតីបុត្រដូចយ៉ាងនោះ ។ ដោយហេតុនោះ លោកទើបពោលថា ព្រះមានព្រះភាគ បានទតព្រះនេត្រឃើញហើយ ។ បទថា **ព្រះមានព្រះភាគ បានត្រាស់នឹងសិង្គាលកគហ-**

**បតីបុត្រ** សេចក្តីថា សិង្គាលកគហបតីបុត្រនោះ មិនឃើញព្រះសាស្តាសូម្បីប្រថាប់ឈរក្នុងទីជិត នៅតែថ្វាយបង្គំទិសទាំងឡាយនុ៎ះឯង ។ លំដាប់នោះព្រះមានព្រះ-ភាគ ទ្រង់ហើបព្រះឱស្ឋ ដូចមហាបទុមកំពុងរីកដោយសម្ផ័ស្សពន្លឺព្រះអាទិត្យ ដូច្នោះ បានត្រាស់ព្រះវាចានេះថា ម្នាលគហបតីបុត្រអ្នកធ្វើអ្វីហ្ន៎ ដូច្នេះជាដើម ។ បទថា **បពិត្រព្រះអង្គ ក៏ក្នុងវិន័យព្រះអរិយ-លោកថ្វាយបង្គំទិស ដូចម្តេច** សេចក្តីថា សិង្គាលកគហបតីបុត្រ ស្តាប់ព្រះតម្រាស់នោះ របស់ព្រះមានព្រះភាគហើយ គិតថា បានឮថាទិសដែលបិតារបស់យើងគប្បីនម-

ស្ការទិស៦នោះ មិនមែនទិសនេះ ន័យថា ព្រះអរិយសាវកនមស្ការទិស៦ យ៉ាងដទៃ ណ្ហើយចុះ យើងនឹងទូលសួរដល់ទិសដែល ព្រះអរិយសាវ័កគប្បីនមស្ការហើយ ទើបនិង នមស្ការ ដូច្នេះ សិង្គាលកគហបតីបុត្រនោះ កាលនឹងទូលសួរដល់ទិសទាំងនោះ ទើប ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ក៏ក្នុង វិន័យរបស់ព្រះអរិយ លោកនមស្ការទិស ដូចម្ដេចជាដើម ។ ក្នុងបទទាំងនោះបទថា **យថា** ត្រឹមតែនិបាត ។

បទថា **កថំ បន** នេះជាបទសួរ ។

## ឧបក្កិលេស៤ យ៉ាង

ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហ-បតីបុត្រ បើដូច្នោះអ្នកចូរស្តាប់ចុះ ចូរកំណ-ត់ទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនិងសម្តែងប្រាប់ ។ សិង្គាលកគហបតីបុត្រក៏ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា

បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតីបុត្រ អរិយសាវ័កលះបង់នូវកម្មក្កិ-លេស(អំពើដ៏សៅហ្មង)៤ប្រការផង មិនធ្វើនូវបាបកម្ម(អំពើអាក្រក់)ព្រោះហេតុ៤យ៉ាងផង មិនសេពនូវអបាយមុខ(គឺប្រធាននៃ-សេចក្តីវិនាស)នៃភោគៈ ៦យ៉ាងផង អរិយ-

សាវ័កនោះ លោកវៀរចាកបាបធម៌ទាំង១៤ យ៉ាងនេះ ឈ្មោះថា ជាអ្នកបិទបាំងទិស ទាំង៦ប្រតិបត្តិដើម្បីជំនះក្នុងលោកទាំងពីរ គឺលោកនេះ ក៏អរិយសាវ័កនោះបានប្រារព្ធ គឺថាបានពេញចិត្តហើយ លោកខាងមុខក៏ពេញចិត្តទៀត ។ លុះអរិយសាវ័កនោះ ទំលាយរាងកាយទៅ រមែងកើតក្នុងមនុស្ស សុគតិសួគ៌ទេវលោក ។ កម្មក្កិលេស៤ប្រការ ដែលអរិយសាវ័កនោះលះបង់ហើយ ដូចម្តេច ។ ម្នាលគហបតីបុត្រ ការធ្វើសត្វ មានជីវិតឲ្យធ្លាក់ចុះកន្លង(សម្លាប់សត្វ) ជា កម្មក្កិលេស១ ការកាន់យកទ្រព្យដែលម្ចាស់ គេមិនឲ្យ ជាកម្មក្កិលេស១ ការប្រព្រឹត្តិខុស

ក្នុងកាមទាំងឡាយ ជាកម្មក្កិលេស១ ការនិយាយពាក្យកុហក ជាកម្មក្កិលេស១ កម្មក្កិលេស ៤ប្រការនេះ ដែលអរិយសាវ័កនោះ បានលះបង់ហើយ ។ ព្រះមានព្រះភាគបានសម្ដែងពាក្យនេះហើយ ព្រះសុគតជាសាស្ដា លុះទ្រង់សម្ដែងពាក្យនេះហើយ ទើបសម្ដែងគាថាព័ន្ធនេះ តទៅទៀតថា ៖

**បាណាតិបាតោ អទិន្នាទានំ មុសាវាទោ**
**បវុច្ចតិ បរទារគមនញ្ចេវ នបសំសន្តិ**
**បណ្ឌិតាតិ ។**

ការសម្លាប់សត្វ១ លួចទ្រព្យគេ១ និយាយកុហក១ សេពភរិយាបុគ្គលដទៃ១ ហៅ

ថា (កម្មក្កិលេស) បណ្ឌិតទាំងឡាយមិន សរសើរឡើយ ។

បទថា **កម្មក្កិលេសទាំងឡាយ** សេចក្តីថា សត្វទាំងឡាយនឹងសៅហ្មងដោយកម្មទាំង-ឡាយប៉ុណ្ណោះ ព្រោះដូច្នោះ លោកទើបពោលថា កម្មក្កិលេសទាំងឡាយ ។

បទថា **ឋានេហិ** ប្រែថា ដោយហេតុទាំង-ឡាយ ។

បទថា **អបាយមុខានិ** ប្រែថា ផ្លូវនៃសេច-ក្តីវិនាស ។ បទថា **អ្នកនោះ** គឺព្រះអរិយសា-វ័កជាសោតាបន្ន ។ បទថា **ចុទ្ទសបាបកាប-គតោ** ប្រែថា ប្រាសចាកបាប គឺសេចក្តីលា-

មកទាំង ១៤ យ៉ាងនេះ ។ បទថា **ឆទិសាប-ដិច្ឆាទី** គឺ បិទបាំងទិស ៦។

បទថា **ឧភោលោកវិជយាយ** សេចក្ដីថា ដើម្បីឈ្នះលោកនេះ និងលោកមុខទាំងពីរ ។

បទថា **និងលោកនេះ ដែលព្រះអរិយសា-វ័កនោះ ប្រារព្ធហើយ** សេចក្ដីថា ពិតហើយ ពៀរវេរាទាំង៥ ក្នុងលោកនេះរមែងមិនមានដល់ព្រះអរិយសាវ័កបែបនោះ ដោយហេតុនោះ លោកនេះ ដែលព្រះអរិយសាវ័កនោះបានប្រារព្ធហើយ គឺបានពេញចិត្តហើយ និងសម្រេចហើយពៀរវេរាទាំងឡាយ៥

រមែងមិនមាន សូម្បីក្នុងលោកខាងមុខ ដោយហេតុនោះ លោកខាងមុខ ក៏ព្រះអរិ-យសាវ័កបានពេញចិត្តហើយ ។ ព្រោះដូច្នោះ ព្រះអរិយសាវ័កនោះ ខាងមុខពីស្លាប់ ព្រោះកាយបែកធ្លាយ រមែងចូលដល់សុគតិសួគ៌ ។ ដោយប្រការដូច្នេះ ព្រះមាន-ព្រះភាគ ទ្រង់តាំងមាតិកាទុកដោយសង្ខេប ឥឡូវនេះ កាលនឹងញ៉ាំងមាតិកាបទនោះឲ្យពិស្តារទើបត្រាស់ថា កម្មក្កិលេស៤ ប្រការដែលព្រះអរិយសាវ័កនោះលះបង់ហើយ

ដូចម្តេចជាដើម ។ បទថា **កម្មក្កិលេសោ** សេចក្តីថា ឈ្មោះថា កម្មក្កិលេស ព្រោះកម្មនោះជាកិលេស ព្រោះសម្បយុត្តដោយ

កិលេស ។ ពិតហើយអ្នកមានកិលេសប៉ុ-ណ្ណោះ រមែងសម្លាប់សត្វ អ្នកមិនមានកិលេ-ស រមែងមិនសម្លាប់សត្វ ព្រោះដូច្នោះ បា-ណាតិបាតលោកទើបពោលថា ជាកម្មក្កិ-លេស ។ សូម្បីកម្មក្កិលេសមាន អទិន្នាទាន ជាដើម ក៏មានន័យនេះឯង ។ បទថា **អថា-បរំ** សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់ គាថាព័ន្ធសម្តែងសេចក្តីនោះតទៅទៀត ។

អរិយសាវ័កមិនធ្វើនូវបាបកម្ម ព្រោះ ហេតុ ៤ យ៉ាង ដូចម្តេចខ្លះ បុថុជ្ជនលុះអគតិ ព្រោះស្រឡាញ់ ក៏ធ្វើបាបកម្ម លុះអគតិ ព្រោះស្អប់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះ ល្ងង់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះខ្លាច ក៏ធ្វើ

បាបកម្ម ។ ម្នាលគហបតីបុត្រ អរិយសាវ័ក មិនលុះអគតិព្រោះស្រឡាញ់ មិនលុះអគតិ ព្រោះស្អប់ មិនលុះអគតិព្រោះល្ងង់ មិនលុះ អគតិព្រោះខ្លាច ព្រោះហេតុទាំង ៤ ណា ។ អរិយសាវ័កនោះឈ្មោះថា មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងនេះ ។ ព្រះមានព្រះភា-គបានសម្តែងពាក្យនេះហើយ ព្រះសុគតជា សាស្តា លុះទ្រង់សម្តែងពាក្យនេះហើយ ទើបសម្តែងគាថាព័ន្ធនេះតទៅទៀតថា ៖

**ឆន្ទា ទោសា ភយា មោហា យោ ធម្មំ**
**អតិវត្តតិ និហីយតិ តស្ស យសោ កាឡបក្ខេវ**
**ចន្ទិមា ។ ឆន្ទា ទោសា ភយា មោហា យោ**

## ធម្មំ នាតិវត្តតិ អាបូរតិ តស្ស យសោ សុក្កបក្ខេវ ចន្ទិមាតិ ។

អ្នកណា ប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះ សេចក្តីវង្វេង យសរបស់អ្នកនោះ រមែងសាបសូន្យទៅ ដូចព្រះច័ន្ទខាងរនោច ។ អ្នកណា មិនប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីវង្វេង យសរបស់អ្នកនោះ រមែងពេញបរិបូណ៌ ដូចព្រះ-ច័ន្ទខាងខ្នើត ។

បទថា **រមែងធ្វើកម្មដ៏លាមក** សេចក្ដីថា ព្រះមានព្រះភាគកាលព្រះអង្គទ្រង់សម្ដែង ដល់បុគ្គលដែលធ្វើហើយ អ្នកមិនធ្វើរមែង ប្រាកដដូច្នោះ សូម្បីទ្រង់តាំងមាតិកាថា ព្រះអរិយសាវ័ក រមែងមិនធ្វើកម្មដ៏លាមក ព្រោះព្រះអង្គទ្រង់ឆ្លាតក្នុងទេសនា កាល នឹងទ្រង់សម្ដែងបុគ្គលដែលធ្វើមុនទើប ត្រាស់បទនេះថា បុគ្គលរមែងធ្វើកម្មដ៏លាម-ក ។ ក្នុងបទទាំងឡាយនោះ បទថា **ដល់-ឆន្ទាគតិ** សេចក្ដីថា ដល់អគតិ ដោយសេច-ក្ដីពេញចិត្ត គឺ ដោយសេចក្ដីស្រឡាញ់ ធ្វើ វត្ថុមិនគួរធ្វើ ។

សូម្បីក្នុងបទដទៃ ក៏មានន័យនេះឯង ។ បទទាំងឡាយនោះអ្នកណាធ្វើអ្នកមិនជាម្ចាស់របស់ ឲ្យជាម្ចាស់របស់ ដោយអំណាចសេចក្ដីពេញចិត្តថា អ្នកនេះជាមិត្តរបស់យើង ជាអ្នកពេញចិត្តនឹងយើង ជាអ្នកគប់រកគ្នាមក ជាញាតិស្និទ្ធរបស់យើង ឬឲ្យរបស់ជាទីពេញចិត្តដល់យើងដូច្នេះ អ្នកនេះដល់នូវឆន្ទាគតិ ឈ្មោះថា **រមែងធ្វើកម្មដ៏លាមក** ។ អ្នកណាធ្វើអ្នកមិនជាម្ចាស់របស់ឲ្យជាម្ចាស់របស់ ដោយអំណាចមានពៀរនឹងគ្នាជាប្រក្រតីថា អ្នកនេះជាអ្នកមានពៀរនឹងយើងដូច្នេះ ឬដោយអំណាចសេចក្ដីក្រោធ ដែលកើតឡើងក្នុងខណៈនោះ អ្នក

នេះដល់នូវទោសាគតិ ឈ្មោះថា **រមែងធ្វើ-កម្មដ៏លាមក** ។ មួយវិញទៀត អ្នកណា ព្រោះជាអ្នកមានបញ្ញាទន់ខ្សោយ ព្រោះភាពជាអ្នកល្ងង់ខ្លៅ និយាយរឿងធ្វើអ្នកមិនជាម្ចាស់របស់ឲ្យជាម្ចាស់របស់ អ្នកនេះដល់មោហាគតិ ឈ្មោះថា **រមែងធ្វើកម្មដ៏លាមក** ។

មួយទៀត អ្នកណាខ្លាចថា អ្នកនេះជារាជវល្លភ ឬជាអ្នកអាស្រ័យនៅនឹងសត្រូវ គប្បីធ្វើសេចក្តីវិនាសដល់យើងដូច្នេះ ហើយធ្វើអ្នកមិនជាម្ចាស់របស់ ឲ្យជាម្ចាស់របស់ អ្នកនេះដល់នូវភយាគតិ ឈ្មោះថា**រមែងធ្វើ-កម្មដ៏លាមក** ។

មួយទៀត ជាអ្នកណាកាលបែងចែករបស់ឯណាមួយ រមែងឲ្យរបស់ដ៏ប្រសើរ ដោយអំណាចសេចក្ដីស្រឡាញ់ថា "អ្នកនេះជាសំឡាញ់របស់យើង ឬរួមស៊ីរួមដេកនិងយើង" រមែងឲ្យរបស់ថោកទាបទៅ ដោយអំណាចសេចក្ដីក្រោធថា អ្នកនេះជាសត្រូវរបស់យើងដូច្នេះ ព្រោះសេចក្ដីល្ងង់ខ្លៅ មិនដឹងរបស់ដែលឲ្យហើយ និងមិនទាន់ឲ្យ រមែងឲ្យរបស់ថោកទាបដល់បុគ្គលខ្លះ ឲ្យរបស់ច្រើនដល់បុគ្គលខ្លះ ព្រោះខ្លាចថា អ្នកនេះកាលយើងមិនឲ្យវត្ថុនេះ គប្បីធ្វើសូម្បីសេចក្ដីវិនាសដល់យើង រមែងឲ្យរបស់ដល់ប្រសើរដល់បុគ្គលខ្លះ អ្នកនោះសូម្បីជាអ្នក

មានអគតិ ៤ យ៉ាងនេះក៏លុះក្នុងអគតិ មានឆន្ទាគតិជាដើមតាមលំដាប់ ឈ្មោះថា **រមែងធ្វើកម្មដ៏លាមក** ។ តែព្រះអរិយសាវ័ក សូម្បីនឹងអស់ជីវិតក៏មិនលុះក្នុងអគតិមានឆន្ទាគតិជាដើម ដោយហេតុនោះ លោកទើបពោល-ថាព្រះអរិយសាវ័ករមែងមិនធ្វើកម្មដ៏លាមកក្នុងឋានៈទាំង ៤ នេះ ។

បទថា **យសរបស់អ្នកនោះរមែងវិនាស** សេចក្តីថា សូម្បីកិត្តិយស សូម្បីបរិវារយសរបស់អ្នក លុះក្នុងអគតិនោះ រមែងសាប -សូន្យ គឺ រមែងវិនាសអស់ ។

# ពោលអំពីអបាយមុខ ៦យ៉ាង

អរិយសាវ័កមិនសេពនូវធម៌ ជាប្រធាននៃសេចក្ដីវិនាសភោគៈ ៦ យ៉ាងដូចម្ដេចខ្លះ ។ ម្នាលគហបតីបុត្រ កិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺ សុរានិងមេរ័យដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ជាប្រធាននៃសេចក្ដីវិនាសភោគៈ១ បានប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ជាប្រធាននៃសេចក្ដីវិនាសភោគៈ១ ការដើរមើលមហោស្រពជាប្រធាននៃសេចក្ដីវិនាសភោគៈ១ ការប្រកបរឿយៗនូវហេតុជាទីតាំង នៃសេចក្ដីប្រមាទ គឺ ជាប្រធាននៃសេចក្ដីវិនាសភោគៈ១ លេងល្បែងភ្នាល់ជា

ប្រធាននៃសេចក្តីវិនាសភោគៈ១ ការសេព-គប់នូវបាបមិត្តជាប្រធាននៃសេចក្តីវិនាសភោគៈ១ ការប្រកបរឿយៗ នូវសេចក្តីខ្ជិលជាប្រធាននៃសេចក្តីវិនាសភោគៈ១ ។

សុរា ៥ ប្រភេទ គឺ សុរាធ្វើដោយនំ សុរាធ្វើដោយម្សៅ សុរាធ្វើដោយបាយ សុរាដាក់មេសុរា សុរាប្រកបដោយគ្រឿងផ្សំផ្សេងៗ ឈ្មោះថា **សុរា** ក្នុងបទនេះថា អ្នកផឹកទឹកស្រវឹង គឺ សុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ដូច្នេះ ។ របស់ត្រាំ ៥ប្រភេទ គឺ របស់ត្រាំដោយផ្កាឈើ របស់ត្រាំដោយផ្លែឈើ របស់ត្រាំដោយផ្អែម របស់ត្រាំដោយទឹកអំពៅ របស់ត្រាំប្រកបដោយ

គ្រឿងផ្សំផ្សេងៗឈ្មោះថា **មេរ័យ** ។ សូម្បីទាំងអស់នោះ ឈ្មោះថា **មជ្ជៈ** ដោយអំណាចធ្វើឲ្យស្រវឹង ។ បទថា **បមាទដ្ឋានំ** គឺហេតុនៃសេចក្តីប្រមាទ ។ បទនេះ ជាឈ្មោះរបស់ចេតនានៃអ្នកផឹកទឹកស្រវឹង។ បទថា **ប្រកបរឿយៗ** អធិប្បាយថា ប្រកបរឿយៗ គឺ ធ្វើញយៗ នូវការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ក៏ព្រោះកាលអ្នកប្រកបរឿយៗក្នុងការផឹកទឹកស្រវឹងនេះ ភោគៈទាំងឡាយដែលកើតឡើងហើយ រមែងវិនាស និងនៅមិនទាន់កើតឡើង រមែងមិនកើតឡើងដូច្នោះ លោកទើបពោលថា ជាផ្លូវវិនាសនៃ

ភោគៈទាំងឡាយ ។ បទថា **វិកាលវិសិខាចរិយានុយោគោ** សេចក្តីថា ភាពជាអ្នកត្រាច់ទៅ ក្នុងចន្លោះផ្លូវដែលជាវិកាល ។ បទថា **ទៅមើលមហោស្រព** គឺ ទៅមើលមហោស្រព ដោយការមើលរបាំជាដើម ។ បទថា **ប្រកបរឿយៗ នូវសេចក្តីខ្ជិលច្រអូស** អធិប្បាយថា ព្រោះភាពជាអ្នកខ្វល់ខ្វាយក្នុងការប្រកបដោយសេចក្តីខ្ជិលច្រអូសផ្លូវកាយ ។

ម្នាលគហបតីបុត្រ ទោសក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទនេះ មាន ៦ យ៉ាង គឺវិនាសទ្រព្យ

ដែលឃើញជាក់ស្តែងខ្លួន១ ការរកឲ្យកើតជម្លោះ១ ហេតុនាំឲ្យកើតរោគទាំងឡាយ១ ការនាំឲ្យខូចឈ្មោះ១ ការបង្ហាញកេរ្តិ៍ខ្មាស ១ ហេតុជាគំរប់ ៦ គឺធ្វើបញ្ញាឲ្យមានកំម្លាំងថយ១ ។ ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទ ៦ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់តាំងមាតិកាបទរបស់ផ្លូវនៃសេចក្តីវិនាស ៦ ប្រការ យ៉ាងនេះហើយ កាលទ្រង់ចែកមាតិកាបទទាំងនោះ ក្នុងឥឡូវនេះ ទើបត្រាស់ថា ម្នាល

គហបតីបុត្រ ទោស ៦ ប្រការនេះឯង ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ដែលខ្លួនឃើញ-បាន** គឺ ការរស់នៅក្នុងលោកនេះដែលខ្លួនគប្បីឃើញ ។ បទថា **ធនជានិ** ប្រែថា វិនាសទ្រព្យ ។ បទថា **បង្កជម្លោះ** សេចក្តីថា បង្កការឈ្លោះដោយវាចា និងការឈ្លោះដោយដៃជាដើម ។ បទថា **ទឹកស្រវឹងជាហេតុឲ្យកើតនៃរោគទាំងឡាយ** សេចក្តីថា ទឹកស្រ-វឹង ជាដែននៃរោគទាំងនោះ មានរោគភ្នែកជាដើម ។ បទថា **ទឹកស្រវឹងជាហេតុឲ្យខូច-ឈ្មោះ** សេចក្តីថាព្រោះជនផឹកទឹកស្រវឹងហើយ រមែងប្រហារសូម្បីមាតាបិតាបាន

រមែងពោលពាក្យដែលមិនគួរពោល សូម្បីដទៃទៀតរមែងធ្វើវត្ថុដែលមិនគួរធ្វើ ដោយហេតុនេះជនទាំងឡាយ ដល់ការតិះដៀលខ្លះ ដាក់ទោសខ្លះ កាត់អវយវៈមានដៃនិងជើងជាដើមខ្លះ ដល់ភាពជាអ្នកខូចកេរ្តិ៍ឈ្មោះក្នុងលោកនេះខ្លះ ក្នុងលោកខាងមុខខ្លះ ។

ដោយប្រការដូច្នេះ សុរានោះទើបឈ្មោះថា **ជាហេតុខូចឈ្មោះរបស់ជនទាំងនោះ ។**

បទថា **ទឹកស្រវឹងជាហេតុមិនដឹងកេរ្តិ៍ខ្មាស់** សេចក្ដីថា ព្រោះទឹកស្រវឹង រមែងញុំាងកេរ្តិ៍ខ្មាស់ដែលគួរលាក់ គួរបិទបាំងឲ្យ

កម្រើកឲ្យវិនាស ព្រោះដូច្នោះលោកទើប ពោលថា ញ៉ាំងហិរិឲ្យកម្រើកដូច្នេះ ។ មួយទៀត អ្នកស្រវឹងស្រាបើកអវយវៈនោះៗ ហើយត្រាច់ទៅបាន ។ ដោយហេតុនោះ សុរានោះលោកទើបពោលថា ជាហេតុមិនដឹងកេរ្តិ៍ខ្មាស់ ព្រោះធ្វើហិរិឲ្យកម្រើក ។ បទថា **ទឹកស្រវឹងជាហេតុឲ្យបញ្ញាទុព្វល** សេចក្តីថា ទឹកស្រវឹងរមែងធ្វើសេចក្តីដឹងថា សត្វមានកម្មជារបស់ខ្លួនឲ្យខ្សោយចុះដូចបញ្ញា របស់ព្រះសាគតត្ថេរដូច្នោះ ព្រោះដូច្នោះ លោកទើបពោលថាទឹកស្រវឹងជាហេតុឲ្យបញ្ញាទុព្វល ។ តែទឹកស្រវឹង មិនអាចធ្វើឲ្យអ្នកបានមគ្គប្បញ្ញាទុព្វលបាន ។

ព្រោះសុរានោះ រមែងមិនចូលទៅខាងក្នុងមាត់របស់លោកដែលសម្រេចមគ្គហើយ ។ បទថា **ឆដ្ឋំ បទំ** ប្រែថា ហេតុជាគម្រប់ ៦ ។

ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយៗ នូវការដើរទៅតាមច្រកល្ហកខុសកាលនេះមាន ៦យ៉ាង គឺអ្នកនោះឈ្មោះថាមិនគ្រប់គ្រងមិនរក្សាខ្លួន១ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាកូនប្រពន្ធ១ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាទ្រព្យសម្បត្តិ១ សេចក្តីរង្កៀសតែងកើតមានក្នុងកន្លែង(ដែលខ្លួនទៅដល់)នោះៗ១ ពាក្យ

មិនពិតតែងធ្លាក់មកត្រូវលើបុគ្គលនោះ[៤]១ បុគ្គលនោះឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន១ ។ ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយ ៗ នូវកិរិយាត្រាច់ទៅតាមច្រកល្ហកខុសកាលមាន៦យ៉ាងនេះឯង ។

បទថា **ឈ្មោះថាមិនគ្រប់គ្រងមិនរក្សាខ្លួន** អធិប្បាយថា ព្រោះបុគ្គល ត្រាច់ទៅខុសកាល រមែងជាន់ដង្គត់និងបន្លាជាដើមខ្លះ ជួបពស់ខ្លះ យក្ខជាដើមខ្លះ សូម្បីសត្រូវដឹងថានឹងទៅកាន់ទីនោះៗ ក៏ឯបចាប់ខ្លួន ឬសម្លាប់ ។ ដោយហេតុនេះទើបឈ្មោះថា

---

[៤] រមែងត្រូវគេចោទបង្កាច់ក្នុងអំពើដែលខ្លួនមិនបានធ្វើសោះ ព្រោះជាន់ដានចោរ ។

**មិនឃុំគ្រងមិនរក្សាខ្លួន** ។ សូម្បីបុត្រនិងភរិយាគិតថា បិតារបស់យើង ស្វាមីរបស់យើង ត្រាច់ក្នុងពេលយប់នឹងពោលទៅថ្វីដល់ខ្លួនយើងដូច្នេះ ។ ដោយហេតុនេះ សូម្បីបុត្រធីតា សូម្បីភរិយារបស់គេ ធ្វើកិច្ចធុរៈក្រៅស្រុកត្រាច់ទៅក្នុងពេលយប់ ក៏រមែងដល់សេចក្តីវិនាស ។ សូម្បីបុត្រភរិយារបស់គេក៏ឈ្មោះថា ជាអ្នកមិនគ្រប់-គ្រងខ្លួន មិនរក្សាខ្លួន ដោយអាការយ៉ាងនេះ ។ បទថា **ទ្រព្យសម្បត្តិ** សេចក្តីថា ពួកចោរដឹងសេចក្តីដែលបរិវារជនព្រមដោយបុត្រភរិយានោះ ត្រាច់ក្នុងពេលយប់នឹងចូលទៅកាន់ផ្ទះដែលគ្មានមនុស្ស នាំយករបស់ដែល

ត្រូវការទៅ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាទ្រព្យសម្បត្តិ ។ បទថា **ដែលគួររង្កៀស** សេចក្តីថា ជាអ្នកដែលគួររង្កៀសថា អ្នកនេះនឹងជាអ្នកធ្វើសូម្បីក្នុងកម្មដ៏លាមកដែលអ្នកដទៃធ្វើ ។ កាលពោលពាក្យថា បុគ្គលទៅដោយទ្វារផ្ទះរបស់អ្នកណាៗ ចោរកម្ម ឬបរទារិកកម្ម[៥] ការគ្រប់សង្កត់ណាដែលអ្នកដទៃធ្វើទុកក្នុងទីនោះ កម្មនោះដែលថាបុគ្គលនេះធ្វើកម្មនោះ សូម្បីមិនពិតមិនមាន ក៏រមែងប្រាកដ គឺ រមែងតាំងនៅក្នុងបុគ្គលនោះ ។ បទថា

---

[៥] អ្នកត្រេចអរចំពោះហើយក្នុងគឺកិលេស អ្នកនូវប្រពន្ធនៃអ្នកដទៃ ។

**ការដើរក្នុងវេលាយប់ ជាហេតុនៃទុក្ខច្រើន**
សេចក្តីថា នរណាៗមិនអាចពោលថា ទុក្ខមានប្រមាណប៉ុណ្ណោះ ទោមនស្សមានប្រមា-ណប៉ុណ្ណោះ របស់អ្នកដែលត្រូវគេរង្កៀសក្នុងបុគ្គលដទៃនោះឯង ។ ដោយប្រការដូច្នេះ អ្នកដើរពេលយប់នោះ ទើបជាអ្នកប្រសព្វហេតុនៃទុក្ខច្រើន គឺ បានទទួលសេចក្តីលំ-បាកច្រើន ។

ម្នាលគហបតីបុត្រ ទោសក្នុងការដើរមើលល្បែងមហោស្រពនេះ ៦ យ៉ាង គឺរបាំក្នុងទីណា ក៏ទៅក្នុងទីនោះ១ ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ១ ការប្រគុំក្នុងទីណា ក៏ទៅក្នុងទីនោះ១ គេប្រជុំនិយាយរឿង

ព្រេងឥតប្រយោជន៍(មានរឿងចម្បាំងនៃមហាភារតៈនិងរឿងនាងសិតាជាដើម)ក្នុងទីណា ក៏ទៅក្នុងទីនោះ១ ល្បែងវាយគង[៦] ក្នុងទីណា ក៏ទៅក្នុងទីនោះ១ ល្បែងវាយរនាតក្នុងទីណា ក៏ទៅក្នុងទីនោះ១ ។ ម្នាលគហបតីបុត្រ ទោសក្នុងកិរិយាដើរមើលល្បែង មហោស្រពមាន ៦ យ៉ាងនេះឯង ។

បទថា **របាំក្នុងទីណា ទៅក្នុងទីនោះ** សេចក្ដីថា របាំមានការរាំ និងល្ខោនជាដើម មាននៅក្នុងទីណា ហើយគប្បីទៅ ក្នុងស្រុកឬនិគមដែលមានរបាំនោះ ។ កាលអ្នកដែលត្រៀមសំពត់ គ្រឿងក្រអូបនិងផ្កាឈើជា-

---

[៦] បើតាមព្យញ្ជនៈគួរប្រែថា ល្បែងលេងទះទៃ គឺច្រៀងប្របកៃ ។

ដើម ក្នុងថ្ងៃនេះ ដោយគិតថា ស្អែកនេះ យើងនិងទៅមើល ការរាំរបស់គេ ជាការចោលការងាររហូតអស់មួយថ្ងៃ ។ រមែងប្រាកដក្នុងទីនោះ រហូតអស់មួយថ្ងៃខ្លះ ពីរថ្ងៃខ្លះ បីថ្ងៃខ្លះ ដោយការមើល ការរាំរបាំ ។ កាលអ្នកដើរពេលយប់ សូម្បីការដល់ព្រមដោយភ្លៀងជាដើម ក៏មិនធ្វើការសាបព្រោះ កាលដល់ការសាបព្រោះជាដើម ភោគៈទាំងឡាយដែលនៅមិនទាន់កើត រមែងមិនកើត ។ កាលផ្ទះមិនមានមនុស្ស ពួកចោរដឹងសេចក្ដីដែលម្ចាស់របស់ផ្ទះទៅខាងក្រៅ រមែងលួចរបស់ដែលត្រូវការយកទៅ ។ ដោយហេតុនោះ ភោគៈសូម្បីកើតដល់គេក៏រមែងវិនាស ។ សូម្បីក្នុងបទថា ចម្រៀងមានក្នុងទីណា ក៏ទៅក្នុងទីនោះ ជាដើម

ក៏មានន័យនេះឯង ។ ការធ្វើផ្សេងៗ របស់ជនទាំងនោះ លោកពោលហើយក្នុង ព្រហ្ម-ជាលសូត្រ ។

ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ នេះមាន ៦ យ៉ាង គឺបុគ្គលនោះបើឈ្នះគេ តែងបានពៀរ១ បើចាញ់គេតែងសោកស្តាយទ្រព្យសម្បត្តិ១ វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក១ កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ១ ពួកមិត្តអាមាត្យ តែងបោះបង់ចោល១ ជាបុគ្គលដែលគេមិនត្រូវការដណ្តឹង ឬឲ្យកូនស្រីព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់ មិនអាចចិញ្ចឹមប្រពន្ធបានទេ១ ។

ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ នេះមាន ៦យ៉ាងនេះឯង ។

បទថា **អ្នកឈ្នះ រមែងមានពៀរ** សេចក្តីថា អ្នកឈ្នះរមែងកាន់យកនូវសំពត់សាដក ឬសំពត់ជួតក្បាលរបស់អ្នកដទៃ ត្រង់កណ្តាលប្រជុំជន ដោយគិតថាយើងឈ្នះហើយដូច្នេះ ។ អ្នកចាញ់រមែងចងពៀរវេរាក្នុងបុគ្គលនោះថា គេមើលងាយយើងនាកណ្តាលប្រជុំជនណ្ហើយចុះ យើងនឹងឲ្យមេរៀនគេដូច្នេះ ។ កាលឈ្នះយ៉ាងនេះរមែងប្រសព្វពៀរវេរា ។ បទថា **អ្នកចាញ់** សេចក្តីថា អ្នកចាញ់រមែងសោកស្តាយដល់សំពត់

ជួត សំពត់សាដក ឬទ្រព្យសម្បត្តិ មានប្រាក់និងមាសជាដើម យ៉ាងដទៃរបស់គេដែលអ្នកដទៃបានយកទៅ គេរមែងសោកស្តាយ ព្រោះទ្រព្យនោះជាហេតុថា ទ្រព្យនោះ បានមានហើយដល់យើងហ្ន៎ ទ្រព្យនោះរមែងមិនមានដល់យើងហ្ន៎ ដូច្នេះ ដោយអាការៈយ៉ាងនេះ អ្នកចាញ់រមែងស្តាយទ្រព្យ បទថា **ពាក្យនិយាយរបស់អ្នក-លេងល្បែងភ្នាល់ ដែលនិយាយក្នុងទីប្រជុំគេមិនស្តាប់មិនជឿ** សេចក្តីថា កាលគេត្រូវសួរព្រោះភាពជាសាក្សីក្នុងទីវិនិច្ឆ័យ ដោយពាក្យមិនគួរជឿ ។ ជនទាំងឡាយ នឹងនាំគ្នានិយាយថា អ្នកនេះជាអ្នកលេងបាស្កាលេង

ល្បែងភ្នាល់ ពួកលោកកុំជឿពាក្យនិយាយរបស់គេ ។ បទថា **ត្រូវមិត្តអាមាត្យមើលងាយ** សេចក្ដីថា ពិតណាស់ពួកមិត្តអាមាត្យនឹងនិយាយចំពោះគេយ៉ាងនេះថា សម្លាញ់ សូម្បីលោកក៏ជាបុត្ររបស់អ្នកមានត្រកូល លេងល្បែងភ្នាល់ ជាអ្នកកាត់ ជាអ្នកទំលាយត្រាច់ទៅមិនសមគួរដល់ជាតិ និងគោត្ររបស់លោក តាំងពីនេះទៅលោកមិនគប្បីធ្វើយ៉ាងនេះ ។ អ្នកលេងល្បែងភ្នាល់នោះ សូម្បីត្រូវគេពោលយ៉ាងនេះ ក៏មិនជឿគេ ។ បន្ទាប់ពីនោះពួកមិត្តនិងសម្លាញ់ទាំងនោះមិនឈរ មិនអង្គុយរួមនិងគេ ។ សូម្បីពួកគេត្រូវសួរដើម្បីជាសាក្សី ក៏មិនព្រម

និយាយ ព្រោះហេតុអ្នកលេងល្បែងភ្នាល់នោះ ។ ដោយអាការយ៉ាងនេះ អ្នកលេងល្បែងភ្នាល់ទើបជាអ្នកត្រូវមិត្តនិងសម្លាញ់មើលងាយ ។ បទថា **អាវាហ និងវិវាហ** សេចក្តីថា អ្នកប្រាថ្នានឹងនាំកូនស្រីទៅពីផ្ទះរបស់គេ ឈ្មោះថា **អាវាហ** អ្នកប្រាថ្នានឹងឲ្យកូនស្រីនៅក្នុងផ្ទះរបស់គេ ឈ្មោះថា **វិវាហ** ។ បទថា **អប្បត្ថិតោ ហោតិ** ប្រែថា មិនមានអ្នកណាប្រាថ្នា ។ បទថា **នាលំ ទារភរណាយ** សេចក្តីថា អ្នកលេងល្បែងភ្នាល់ មិនអាចនឹងចិញ្ចឹមភរិយាបាន ។ សេចក្តីថា សូម្បីឲ្យស្រីក្រមុំនៅក្នុងផ្ទះរបស់គេ សូម្បី

មកពីផ្ទះរបស់គេ ពួកយើងក៏នឹងគប្បីចិញ្ចឹមរក្សាបាន ។

ម្នាលគហបតីបុត្រ ទោសក្នុងការសេពគប់នូវបាបមិត្តនេះ មាន ៦ យ៉ាង គឺពួកជនដែលជាអ្នកលេងល្បែងភ្នាល់១ ជនដែលជាអ្នកលេងស្រី[៧]១ ជនដែលជាអ្នកលេងផឹកសុរា១ ជនដែលជាអ្នកបោកប្រាស់បញ្ឆោតអ្នកដទៃ ដោយរបស់ក្លែង១ ជនដែលជាអ្នកបំបាត់ប្រវញ្ចន៍អ្នកដទៃ ក្នុងទីចំពោះមុខ១ ជនដែលជាអ្នកឆក់ដណ្តើមទ្រព្យអ្នកដទៃ១ ជនទាំងនោះជាមិត្តជាសំឡាញ់របស់នោះ

---

[៧] អ្នកលេងមាន៤យ៉ាង គឺអ្នកលេងស្រី១ អ្នកលេងភត្ត១ អ្នកលេងផឹកស្រា១ អ្នកលេងមើមឈើ មានស៊ីមើមដំឡូងជាដើម១ ។

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

។ ម្នាលគហបតីបុត្រ ទោសក្នុងការសេព គប់នូវបាបមិត្ត មាន ៦ យ៉ាងនេះឯង ។

បទថា **ធុត្តា** គឺ អ្នកលេងល្បែងភ្នាល់ ។ បទថា **សោណ្ឌា** សេចក្តីថា អ្នកលេងស្រី អ្នកលេងភត្ត អ្នកផឹកស្រា អ្នកលេងមើម ឈើ ។ បទថា **បិបាសា** ប្រែថា អ្នកផឹកស្រា ។ បទថា **នេកតិកា** គឺ បញ្ឆោតដោយរបស់ ក្លែងក្លាយ ។ បទថា **វញ្ចនិកា** គឺ ជាអ្នក ប្រវញ្ចន៍ ដោយការ ប្រវញ្ចន៍ចំពោះមុខ ។ បទថា **ជាអ្នកឆក់ដណ្តើមទ្រព្យរបស់ដទៃ** សេចក្តីថា ជាអ្នកធ្វើការងាររួមនិងអ្នកដែល នៅក្នុងអាគារជាមួយគ្នាជាដើម ។ បទថា **ពួកនោះជាមិត្តរបស់គេ** គឺ គេមិនត្រេកអរ

នឹងអ្នកដទៃដែលជាមនុស្សល្អចូលទៅរក មិត្តលាមកទាំងនោះតែម្យ៉ាង ដូចជ្រូកដែល គេប្រដាប់ដោយរបស់ក្រអូប និងផ្កាឈើ ជាដើម ហើយឲ្យដេកលើទីដេកយ៉ាងល្អ ក៏ នៅចូលទៅកាន់រណ្ដៅលាមកដូច្នេះ ព្រោះ ដូច្នោះ អ្នកសេពគប់មិត្តអាក្រក់រមែងចូល ដល់សេចក្ដីវិនាសជាច្រើន ទាំងក្នុងភពនេះ និងភពមុខ ។

ម្នាលគហបតីបុត្រ ទោសនៃការប្រកប រឿយៗនូវសេចក្ដីខ្ជិលនេះមាន ៦យ៉ាង គឺ មិនធ្វើការងារដោយអាងថា ត្រជាក់ណាស់ ១ មិនធ្វើការងារដោយអាងថា ក្ដៅណាស់ ១ មិនធ្វើការងារដោយអាងថា ល្ងាចណាស់

១ មិនធ្វើការងារដោយអាងថា ព្រឹកណាស់ ១ មិនធ្វើការងារដោយអាងថា ឃ្លានណាស់ ១ មិនធ្វើការងារដោយអាងថា ស្រេកណាស់១ កាលបើជនអ្នកខ្ជិលច្រអូសនោះច្រើនដោយពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើត ក៏ខានកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវសេចក្តីរេចរឹលទៅវិញផង ។ ម្នាលគហបតីបុត្រ ទោសនៃការប្រកបរឿយៗនូវសេចក្តីខ្ជិលនេះមាន ៦យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសម្តែងធម៌នេះហើយ ព្រះសុគតជាសាស្តា លុះ

សម្តែងធម៌នេះហើយ ទ្រង់សម្តែងគាថាព័ន្ធនេះតទៅទៀតថា ៖

**ហោតិ បានសខា នាម ហោតិ សម្មិយ**
**សម្មិយោ យោ ច អត្ថេសុ ជាតេសុ**
**សហាយោ ហោតិ សាសខា ។**
**ឧស្សូរសេយ្យា បរទារសេវនា វេរប្បសំគោ ច**
**អនត្ថតា ច បាបា ច មិត្តា សុកទរិយតា ច**
**ឯតេឆឋានា បុរិសំ ធំសយន្តិ ។ បាបមិត្តោ**
**បាបសខោ បាបអាចារគោចរោ អស្មា**
**លោកា បរម្ហា ច ឧភយា ធំសតេ នរោ ។**
**អក្ខិត្ថិយោ វារុណី នច្ចគីតំ ទិវាសោប្បំ**
**បារិចរិយំ អកាលេ បាបា ច មិត្តា**
**សុកទរិយតា ច ឯតេឆឋានា បុរិសំ ធំសយន្តិ**

។ អក្ខេហិ ទិព្វន្តិ សុរំ បិវន្តិ យន្តិត្ថិយោ
បាណសមា បរេសំ និហីនសេវី ន ច វុឌ្ឍិសេវី
និហីយតិ កាឡបក្ខេវ ចន្ទិមា ។ យោ វារុណិ
អធនោ អកិញ្ចនោ បិបាសោសិ អត្ថបាគតោ
ឧទកមិវ ឥណំ វិគាហតិ អាកុលំ កាហតិ
ខិប្បមត្តនោ ។ ន ទិវាសុប្បសីលេន
រត្តិនុដ្ឋានទេស្សិនា និច្ចំ មត្តេន សោណ្ឌេន
សក្កា អាវសិតុំ ឃរំ ។ អតិសីតំ អតិឧណ្ហំ
អតិសាយមិទំ អហុ ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា
អច្ចេន្តិ មាណវេ ។ យោ ច សីតញ្ច ឧណ្ហញ្ច
តិណា ភិយ្យោ ន មញ្ញតិ ករំ បុរិសកិច្ចានិ
សោ សុខា ន វិហាយតីតិ ។

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

បុគ្គលខ្លះ ជាមិត្តសំឡាញ់បានតែក្នុងរោងសុរាក៏មាន បុគ្គលខ្លះថា សំឡាញ់ៗតែនៅចំពោះមុខក៏មាន បុគ្គលណា កាលបើប្រយោជន៍(ខ្លួន)កើតឡើង ទើបធ្វើជាសំឡាញ់បុគ្គលនោះមកជាសំឡាញ់នឹងខ្លួនក៏មាន ។ កិរិយាដេកដល់ថ្ងៃ១ ធ្វើសេវនកិច្ចនឹងប្រពន្ធអ្នកដទៃ១ ភាវៈជាអ្នកមានពៀរច្រើន១ ភាវៈជាអ្នកធ្វើអំពើឥតប្រយោជន៍១ បាបមិត្ត១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ១ ហេតុទាំង ៦នុ៎ះ រមែងបំផ្លាញ់បុរស(ឲ្យ-វិនាស) ។ នរជនដែលមានមិត្តអាក្រក់មានសំឡាញ់អាក្រក់ មានមារយាទនឹងគោចរអាក្រក់ តែងវិនាសចាកលោកទាំងពីរ គឺ

លោកនេះ និងលោកខាងមុខ ។ ល្បែងភ្នាល់ ល្បែងស្រី និងល្បែងសុរា១ របាំនិងចម្រៀង១ ការដេកថ្ងៃ១ ការឲ្យគេបំរើខ្លួនក្នុងកាលមិនគួរ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ១ ហេតុទាំង៦ នេះតែងបំផ្លាញបុរសវិនាស ។ ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រី ដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប (ខាតលក្ខណ៍) មិនសេពគប់នឹងបុគ្គលដែលមានសេចក្តីចំរើន (គ្រប់លក្ខណ៍)យសរបស់ពួកជននោះតែងសាបសូន្យដូចព្រះចន្ទខាងរនោច ។ ជនដែលជាអ្នកផឹកសុរា ជាអ្នក

ខ្សត់ទ្រព្យ ជាអ្នកឥតមានកង្វល់ដោយការ-ងារចិញ្ចឹមជីវិតមានតែស្រវឹងជានិច្ច ប្រាសចាកសេចក្ដីចំរើន លិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះទៅក្នុងទឹក បុគ្គលនោះ តែងធ្វើការងារឲ្យវឹកវរដល់ខ្លួនដោយឆាប់ ។ បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះត្រជាក់ណាស់ ក្ដៅណាស់ ល្ងាចណាស់ ។ ជនណាមួយធ្វើនូវកិច្ចការ របស់បុរស មិន

អើពើនូវត្រជាក់និងក្តៅក្រៃលែងជាងស្មៅ (ទៅទៀត)ជននោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។

បទថា អាងថា ត្រជាក់ពេកមិនធ្វើការងារ សេចក្តីថា ពួកមនុស្សក្រោកឡើងពីព្រឹកព្រលឹមនិយាយថា ម្នាលអ្នកដ៏ចម្រើន មកទៅធ្វើការងារជាមួយគ្នាចុះ អ្នកខ្ជិលច្រអូសនឹងនិយាយថា នៅត្រជាក់ណាស់ឆ្អឹងនិងបែក ពួកអ្នកនាំគ្នាទៅចុះ យើងនឹងទៅជាខាងក្រោយ ហើយអង្គុយអាំងភ្លើង ។ មនុស្សទាំងនោះ ក៏ទៅធ្វើការងារ ។ ការងាររបស់អ្នកខ្ជិលច្រអូសរមែងមិនវិនាស ។

សូម្បីក្នុងបទទាំងឡាយថា ក្តៅពេក ក៏មាន ន័យនេះឯង ។

បទថា **ឈ្មោះថា មិត្តផឹកស្រាក៏មាន** សេចក្តីថា បុគ្គលខ្លះជាមិត្តសម្លាញ់គ្នាបាន តែក្នុងពាងស្រា ដែលជាកន្លែងផឹកនុ៎ះឯង ។ បាឋៈថា **បន្នសខា** ដូច្នេះ ក៏មាន ។ សេចក្តី ដូចគ្នា ។

បទថា **មិត្តពោលតែមាត់ថា មិត្តៗ ក៏មាន** សេចក្តីថា អ្នកខ្លះនិយាយថា សម្លាញ់ សម្លាញ់ជាសម្លាញ់ចំពោះមុខប៉ុណ្ណោះ កំបាំងមុខដូចជាសត្រូវ រមែងស្វែងរកឱ- កាសតែម្យ៉ាង ។ បទថា **កាលប្រយោជន៍-**

**ទាំងឡាយកើតឡើង** សេចក្តីថា កាលកិច្ច បែបនោះកើតឡើងហើយ ។ បទថា **វេរប្បសង្គា** ប្រែថា ច្រើនដោយពៀរវេរា ។ បទថា **អនត្ថតា** ប្រែថា ធ្វើសេចក្តីវិនាស ។ បទថា **ភាពជាអ្នកកំណាញ់ស្វិត** សេចក្តីថា ភាពជាអ្នកកំណាញ់ស្វិតស្វាញ គឺ ភាពជាអ្នកកំណាញ់ខ្លាំង ។ បទថា **លិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះក្នុងទឹក ដូច្នោះ** សេចក្តីថា គេលិចចុះកាន់បំណុល ដូចដុំថ្មលិចចុះក្នុងទឹក ដូច្នោះ ។ បទថា **ធុញទ្រាន់ក្នុងការក្រោកឡើងពេលយប់** គឺ មិនក្រោកឡើងក្នុងពេលយប់ជាប្រក្រតី ។

បទថា **អាងថាល្ងាចពេក** គឺ គេពោល យ៉ាងនេះថា វេលានេះល្ងាចណាស់ហើយ មិនធ្វើការងារ ។ បទថា **លះបង់ការងារ** គឺ និយាយយ៉ាងនេះហើយ មិនធ្វើការងារ ។

បទថា **ប្រយោជន៍រមែងកន្លងហួស-មាណពទាំងឡាយ** សេចក្ដីថា ប្រយោជន៍-ទាំងឡាយ រមែងកន្លងហួសបុគ្គលបែបនេះ គឺ មិនតាំងនៅក្នុងបុគ្គលទាំងនោះ ។

បទថា តិណ្ណា **ភិយ្យោ** ប្រែថា ក្រៃលែងជាងស្មៅ ។ បទថា **គេរមែងវិនាសចាក-សេចក្ដីសុខ** សេចក្ដីថា បុរសនោះរមែងមិនលះបង់សេចក្ដីសុខ រមែងជាអ្នកសម្បូរណ៍

ដោយសេចក្តីសុខតែម្យ៉ាង ។ ព្រះមានព្រះ-ភាគ ទ្រង់សម្តែង សេចក្តីនេះ ដោយកថាមគ្គនេះ ។ អ្នកគ្រប់គ្រងផ្ទះមិនគួរធ្វើកម្មនេះ ឈ្មោះសេចក្តីចម្រើនរមែងមិនមានដល់អ្នកធ្វើ អ្នកធ្វើ រមែងបានទទួលការតិះដៀលតែម្យ៉ាង ទាំងក្នុងលោកនេះ និងលោកខាងមុខ ។

ម្នាលគហបតីបុត្រ អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ពួកនេះគឺ អ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួនថា មិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម ១ អ្នកត្រូវស្គាល់មនុស្សល្អតែសម្តីថា មិនមែនជាមិត្ត គ្រាន់តែជាមិត្ត

ជាមិត្តប្លម១ អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្ដោយឲ្យគាប់ចិត្តថា មិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម១ អ្នកត្រូវស្គាល់មនុស្សជាសំឡាញ់ ក្នុងការវិនាសភោគៈទាំងឡាយថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម១ ។

ឥឡូវនេះព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងដល់អ្នកមិនមែនមិត្ត ជាមិត្តប្លម ជាជនពាលថាបុគ្គលណាធ្វើយ៉ាងនេះ សេចក្ដីវិនាសរមែងកើតឡើងដល់បុគ្គលនោះ ឬភ័យយ៉ាងដទៃៗ អន្តរាយណាៗ ឧបសគ្គណាៗ ទាំងអស់នោះ រមែងកើតឡើងព្រោះអាស្រ័យបុគ្គលពាល ព្រោះដូច្នោះមិន

គួរសេពគប់បុគ្គលពាលបែបនោះដូច្នេះទើប ត្រាស់ពាក្យជាដើមថា បុគ្គលមិនមែនមិត្ត មាន ៤ ពួកទាំងនេះ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អ្នកគិតតែប្រយោជន៍ខ្លួន** សេចក្តីថា ខ្លួនឯងមានដៃទទេមកហើយ ក៏នាំយកចំណែករបស់យ៉ាងណាមួយទៅ ។ បទថា **ល្អតែសម្តី** សេចក្តីថា ដូចជាអ្នកឲ្យធ្វើត្រឹមតែពាក្យនិយាយប៉ុណ្ណោះ ។ បទថា **អ្នកអែបអប** គឺ រមែងនិយាយចាក់បណ្តោយ ។ បទថា **អ្នកនាំក្នុងផ្លូវវិនាស** គឺ ជាមិត្ត ក្នុងផ្លូវវិនាសនៃភោគៈទាំងឡាយ ។

ម្នាលគហបតីបុត្រ មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិន

ប្លម(នោះ)អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាង គឺមិត្តគិតយកតែប្រយោជន៍ខ្លួន១ មិត្តប្រាថ្នាយករបស់ច្រើនដោយ(ឲ្យ)របស់តិចតួច១ ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត១ សេពគប់មិត្តព្រោះហេតុតែប្រយោជន៍១ ។ ម្នាលគហបតីបុត្រ មិត្តគិតយកតែប្រយោជ-ន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងដល់អ្នកដែលមិនមែនមិត្ត ៤ពួក យ៉ាងនេះហើយ កាលនឹងទ្រង់ចែកហេតុមួយៗ ក្នុងអ្នកដែលមិនមែនមិត្តនោះ ដោយហេតុ ៤ យ៉ាងទើប

ត្រាស់ពាក្យជាដើមថា ម្នាលគហបតីបុត្រ ដោយឋានៈ ៤ យ៉ាង ដូច្នេះ ។

ក្នុងបទទាំងឡាយនោះ បទថា **ជាអ្នកគិតតែប្រយោជន៍ខ្លួន** សេចក្តីថា ជាអ្នកនាំទៅដោយចំណែកតែមួយប៉ុណ្ណោះ ។ សេចក្តីថា ជាអ្នកមានដៃទទេមកកាន់ផ្ទះរបស់សម្លាញ់ ហើយនិយាយដល់គុណរបស់សំពត់សាដក ដែលខ្លួនស្លៀកជាដើម ។ មិត្តគិតតែប្រយោជន៍ខ្លួននោះ និយាយថា«នែ៎សម្លាញ់ អ្នកនោះ រមែងពោលដល់គុណរបស់សំពត់ផ្ទាំងនេះនឹងលោក» ដូច្នេះ ហើយស្លៀកសំពត់ផ្ទាំងដទៃឲ្យផ្ទាំងនោះទៅ ។ បទថា **ឲ្យរបស់តិចគិតយករបស់ច្រើន** គឺ ឲ្យរបស់

ណាមួយតែបន្តិចបន្តួច ហើយប្រាថ្នារបស់ច្រើនពីគេ ។ បទថា **កាលមានភ័យ រមែងធ្វើកិច្ច** សេចក្តីថា កាលភ័យកើតឡើងដល់ខ្លួន រមែងធ្វើកិច្ចនោះៗ ដូចជាទាសៈរបស់គេ, មិត្តគិតយកតែប្រយោជន៍ខ្លួននេះ មិនធ្វើក្នុងកាលទាំងពួង កាលភ័យកើតឡើង ទើបធ្វើ មិនធ្វើដោយសេចក្តីស្រឡាញ់ ព្រោះដូច្នោះ ទើបឈ្មោះថា មនុស្សមិនមែនជាមិត្ត ។ បទថា **សេពគប់មិត្ត ព្រោះឃើញដល់ប្រយោជន៍** សេចក្តីថា មិនសេពគប់ ដោយអំណាចជាមិត្តដ៏ជិតដិត, ប្រាថ្នាប្រយោជន៍របស់ខ្លួនតែម្យ៉ាង ទើបសេពគប់ ។

## បុគ្គលមិនមែនជាមិត្តមាន ៤ពួក

ម្នាលគហបតីបុត្រ មិត្តល្អតែសម្តី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ គឺមិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ១ ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ១ សង្គ្រោះដោយអំពើឥតប្រយោជន៍ កាលកិច្ចទាំងឡាយ កើតឡើងភ្លាម ៗ ក៏សំដែងអាងរបស់ខូចខាត[៨] ១ ម្នាលគហបតីបុត្រ មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្ត

---

[៨] ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វីៗ ក៏ប្រាប់ថារបស់នោះ ខូចនេះបាត់នោះជាដើម ។

ប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

បទថា **អាងយករបស់ដែលកន្លងហើយមកប្រាស្រ័យ** សេចក្ដីថា មិត្តល្អតែសំដីរមែងសង្គ្រោះដោយវត្ថុដែលកន្លងហើយយ៉ាងនេះថា កាលសំឡាញ់មក កាលវេលានេះលោកមិនមក វេលានេះ ស្រូវរបស់ពួកយើងសម្រេចរៀបរយ ពួកយើងតាំងស្រូវសាលី ស្រូវដំណើប និងពូជជាដើមជាច្រើនហើយអង្គុយមើលផ្លូវ តែថ្ងៃនេះអស់ទៅទាំងអស់ហើយ ដូច្នេះ ។ បទថា **អាងវត្ថុដែល-នៅមិនទាន់មាន មកប្រាស្រ័យ** សេចក្ដីថា មិត្តល្អតែសម្ដី រមែងសង្គ្រោះដោយវត្ថុដែល

នៅមិនទាន់មកដល់ យ៉ាងនេះថា ក្នុងថ្ងៃនេះស្រូវរបស់យើងនឹងជាទីរីករាយចិត្ត កាលយើងធ្វើការសង្គ្រោះដោយស្រូវ មានស្រូវសាលីជាដើម ជាការមានផលបរិបូណ៌ហើយ យើងនឹងអាចដើម្បីធ្វើការសង្គ្រោះដល់ពួកលោកបានដូច្នេះ ។ បទថា **មិត្តល្អ - តែសម្តី សង្គ្រោះដោយវត្ថុដែលរកប្រយោជ-ន៍មិនបាន** សេចក្តីថា មិត្តល្អតែសម្តី អង្គុយលើដំរី ឬលើខ្នងសេះ គ្រាឃើញសំឡាញ់ហើយ ពោលថាសំឡាញ់អើយ សំឡាញ់ចូរមកអង្គុយក្នុងទីនេះចុះ មិត្តល្អតែសំដីស្លៀកសំពត់សាដកផ្ទាំងដែលល្អ ហើយពោលថាសំពត់ផ្ទាំងនេះ សមគួរដល់សំឡាញ់របស់

យើងពិតហ្ន៎ តែយើងមិនមានសំពត់ផ្ទាំងដទៃ ។ យ៉ាងនេះ ឈ្មោះថា សង្គ្រោះដោយវត្ថុមិនមានប្រយោជន៍ ។ បទថា **កាលកិច្ច-ទាំងឡាយកើតឡើង សម្ដែងការខូចខាតពឹងមិនបាន** សេចក្ដីថា កាលមានអ្នកពោលថា ខ្ញុំត្រូវការរទេះ មិត្តល្អតែសំដី ពោលពាក្យជាដើមថា ស្ដាយណាស់ កង់រទេះភ្លៅរទេះបាក់ហើយ ។

ម្នាលគហបតីបុត្រ មិត្តនិយាយចាក់បណ្ដោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាង គឺបើមិត្តនិយាយអាក្រក់ ក៏យល់ព្រមតាម១ មិត្តធ្វើអំពើល្អក៏យល់ព្រម

តាម១ ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមុខ ១ ពោលទោសមិត្ត ក្នុងទីកំបាំងមុខ១ ។ ម្នាលគហបតីបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤យ៉ាងនេះឯង ។

បទថា **មិត្តអែបអប តាមចិត្តមិត្តឲ្យធ្វើអាក្រក់** សេចក្តីថា កាលសំឡាញ់និយាយថា ពួកយើងនឹងធ្វើបាណាតិបាតជាដើមយ៉ាងណាមួយ មិត្តអែបអប ក៏យល់ព្រមតាមចិត្តមិត្ត ដោយពាក្យថា “ល្អហើយសំឡាញ់ធ្វើចុះ” ។ សូម្បីក្នុងការធ្វើល្អ ក៏មានន័យនេះឯង ។

ម្នាលគហបតីបុត្រ មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាង គឺ ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរាមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ១ ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល១ ជាសំឡាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព១ ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយៗ នូវល្បែងភ្នាល់ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ១ ។ ម្នាលគហ-បតីបុត្រមនុស្សជាសំឡាញ់ក្នុងផ្លូវវិនាសមិនមែនជាមិត្តទេគ្រាន់តែជាមិត្តប្លម អ្នកត្រូវ

ស្គាល់ដោយស្ថាន៤យ៉ាងនេះឯង ។ ព្រះ-
មានព្រះភាគទ្រង់បានសំដែងសេចក្តីនេះ
លុះព្រះសុគតជាសាស្តាសំដែងសេចក្តីនេះ
ហើយ ទើបទ្រង់សំដែងពាក្យគាថាព័ន្ធ
តទៅទៀតថា៖

**អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរមោ**
**អនុប្បិយញ្ច យោ អាហុ អបាយេសុ ច យោ**
**សខា ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ**
**បណ្ឌិតោ អារកា បរិវជ្ជេយ្យ មគ្គំ បដិភយំ**
**យថាតិ ។**

បុគ្គលដែលជាមិត្ត គិតយកតែប្រយោជន៍
ខ្លួន ១ បុគ្គលដែលជាមិត្តល្អតែសំដី១

បុគ្គលដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត១ បុគ្គលដែលជាសំឡាញ់ក្នុងផ្លូវវិនាស១ បណ្ឌិតដឹងថាបុគ្គលទាំង ៤ ពួកនុ៎ះមិនមែនជាមិត្តហើយ គប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នេះ ។

បទថា **ជាសំឡាញ់** សេចក្តីថា កាលសំឡាញ់និយាយថា ជនទាំងឡាយនាំគ្នាផឹកស្រាក្នុងទីឯណោះ លោកចូរមក យើងនឹងទៅក្នុងទីនោះ អ្នកបបួលក្នុងផ្លូវវិនាសទទួលថា ល្អហើយ ហើយក៏ទៅ ។ ក្នុងបទទាំងពួង ក៏មានន័យនេះ ។ បទថា **បណ្ឌិត**

**ដឹងច្បាស់យ៉ាងនេះហើយ** សេចក្តីថា ដឹងយ៉ាងនេះថា ពួកនេះមិត្តប្លម ដូច្នេះ ។

## មិត្ត ៤ពួកមានសន្តានល្អ

ម្នាលគហបតីបុត្រ មនុស្ស៤ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ គឺមិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១ មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ១ មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ១ មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ១ ។

ព្រះមានព្រះភាគ ត្រាទ្រង់សម្តែងមិត្តអាក្រក់ មិនគួរសេពគប់យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងមិត្តល្អ គួរសេពគប់ក្នុងឥឡូវនេះ ទើបត្រាស់ពាក្យជាដើមថា **ម្នាលគហបតីបុត្រ មិត្តល្អមាន ៤ពួកទាំងនេះទៀត** ។

ក្នុងបទទាំងពួង បទថា **សុហទា** ប្រែថា មិត្តមានចិត្តល្អ។

ម្នាលគហបតីបុត្រ មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤យ៉ាង គឺ រក្សាមិត្តដែលធ្វេសប្រហែស១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស១

ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិត ភ័យ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើង ហើយ តែងជួយផ្តល់ភោគៈជាទ្វេគុណជាង ទ្រព្យដែលមិត្តត្រូវការនោះ១ ។ ម្នាលគហ-បតីបុត្រ មិត្តមានឧបការៈ ជាមិត្តមាន សន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤យ៉ាង នេះឯង ។

បទថា **រក្សាមិត្តដែលប្រមាទហើយ** សេចក្តីថា មិត្តមានឧបការៈ ឃើញសំឡាញ់ ផឹកទឹកស្រវឹងហើយដេកត្រង់កណ្តាលស្រុក ត្រង់ទ្វារស្រុក ត្រង់ផ្លូវ គិតថា កាលសំឡា-ញ់ដេកយ៉ាងនេះ នរណាៗ គប្បីលួចសូម្បី សំពត់ស្លៀក និងសំពត់ដណ្តប់ ដូច្នេះ ទើប

អង្គុយជិតសំឡាញ់ កាលសំឡាញ់ភ្ញាក់ក៏នាំទៅ ។ បទថា រក្សាទ្រព្យរបស់មិត្តដែលប្រមាទ សេចក្តីថា មិត្តមានឧបការៈគិតថា សំឡាញ់ទៅខាងក្រៅ ឬផឹកស្រាស្រវឹង ផ្ទះមិនមានអ្នកចាំ នរណាៗ នឹងគប្បីលួចរបស់ណាមួយទៅ ដូច្នេះ ទើបចូលទៅកាន់ផ្ទះការពារទ្រព្យរបស់សំឡាញ់នោះ ។ បទថា កាលមានភ័យក៏ជាទីពឹងរបស់មិត្តបាន សេចក្តីថា កាលភ័យណាមួយកើតឡើង មិត្តមានឧបការៈពោលថា កុំខ្លាច កាលសំឡាញ់ដូចយើងនៅមាន លោកនឹងខ្លាចអ្វី ហើយកម្ចាត់ភ័យនោះចេញទៅ ជាទីពឹងពាក់បាន ។ បទថា ផ្តល់ទ្រព្យឲ្យទ្វេគុណ

សេចក្តីថា កាលកិច្ចដែលគួរធ្វើកើតឡើង មិត្តមានឧបការៈឃើញសំឡាញ់មករកខ្លួន ហើយ សួរថា ព្រោះហេតុអ្វីលោកទើបមក ។ មានការងារក្នុងរាជត្រកូល ។ លោកគួរនឹងបានអ្វី សូម ១កហាបណៈ ។ ធម្មតាការ-ងារក្នុងក្រុង នឹងមិនសម្រេចត្រឹមតែមួយកហាបណៈ លោកចូរយក ២កហាបណៈចុះ ។ គេឲ្យ ២ដងតាមដែលនិយាយ ។

ម្នាលគហបតីបុត្រ មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត១ មិនបោះបង់គ្នា ក្នុងគ្រាមានវិបត្តិ សូម្បីជីវិត

ក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត(ស៊ូប្តូរជីវិត) ។ ម្នាលគហបតីបុត្រ មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤យ៉ាងនេះឯង ។

បទថា **ប្រាប់អាថ៌កំបាំងដល់មិត្ត** សេចក្តីថា មិនប្រាប់រឿងដែលគួរបិទបាំង សេចក្តីកំបាំងរបស់ខ្លួនដល់អ្នកដទៃ ហើយប្រាប់ដល់សម្លាញ់ប៉ុណ្ណោះ ។ បទថា **បិទបាំងអាថ៌កំបាំងរបស់មិត្ត** សេចក្តីថា មិត្តមានឧបការៈ រមែងរក្សាសេចក្តីកំបាំងដែលសំឡាញ់ពោល ដែលអ្នកដទៃមិនដឹង ។ បទថា **មិនលះបង់គ្នាក្នុងកាលមានអន្តរាយ** សេចក្តីថា កាលភ័យកើតឡើង មិត្តមានឧបការៈ រមែង

មិនលះបងចោល ។ បទថា **សូម្បីជីវិត ក៏លះបង់ដើម្បីប្រយោជន៍ដល់មិត្ត** សេចក្តីថា សូម្បីជីវិតរបស់ខ្លួន ក៏ជារបស់មិត្តរួមសុខរួមទុក្ខ លះបង់ដើម្បីប្រយោជន៍ដល់សំឡាញ់បាន មិត្តរួមសុខរួមទុក្ខ មិនគិតដល់ជីវិតរបស់ខ្លួន ធ្វើការងារឲ្យដល់សំឡាញ់តែម្យ៉ាង ។

ម្នាលគហបតីបុត្រ មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤យ៉ាង គឺ ហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់១ ដឹកនាំឲ្យមិត្តតំកល់នៅតែក្នុងអំពើល្អ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ១ ប្រាប់ផ្លូវឋានសួគ៌១ ។ ម្នាលគហបតីបុត្រ

មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤នេះឯង ។

បទថា **មិត្តហាមសេចក្ដីអាក្រក់** សេចក្ដីថា មិត្តណែនាំប្រយោជន៍ រមែងហាមថា កាលយើងឃើញលោកនឹងមិនបានធ្វើយ៉ាងនេះ លោកកុំធ្វើពៀរវេរាទាំង៥ អកុសលកម្មបថ១០ឡើយ ។ បទថា **ឲ្យតាំងនៅក្នុងសេចក្ដីល្អ** សេចក្ដីថា មិត្តណែនាំប្រយោជន៍ រមែងឲ្យប្រកបសេចក្ដីល្អ យ៉ាងនេះថា លោកចូរប្រព្រឹត្តទៅក្នុងកម្មល្អ ក្នុងសរណៈ ៣ ក្នុងសីល ៥ ក្នុង កុសលកម្មបថ ១០ លោកចូរឲ្យទាន ចូរធ្វើបុណ្យ ចូរស្ដាប់ធម៌ដូច្នេះ ។ បទថា **ឲ្យស្ដាប់ពាក្យដែលមិនធ្លាប់**

**ស្តាប់** គឺ ឲ្យស្តាប់ពាក្យដែលល្អិតល្អន់ ធ្វើឲ្យឆ្លាតក្នុងវត្ថុមិនធ្លាប់បានស្តាប់ ។ បទថា **ប្រាប់ផ្លូវសួគ៌** សេចក្តីថា មិត្តណែនាំប្រយោជន៍ រមែងប្រាប់ផ្លូវសួគ៌ យ៉ាងនេះថា ជនទាំងឡាយ ធ្វើកម្មនេះ រមែងកើតក្នុងឋានសួគ៌ ។

ម្នាលគហបតីបុត្រ មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត១ ។

ម្នាលគហបតិបុត្រ មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតជាសាស្តាសំដែងសេចក្តីនេះហើយ ទើបទ្រង់សំដែងពាក្យគាថាព័ន្ធ តទៅទៀតថា៖

**ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ**
**សខា អត្ថក្ខាយី ច យោ មិត្តោ យោ ច**
**មិត្តនុកម្បកោ ។ ឯតេបិ មិត្តេ ចត្តារោ ឥតិ**
**វិញ្ញាយ បណ្ឌិតោ សក្កច្ចំ បយិរូបាសេយ្យ**
**មាតា បុត្តំវ ឱរសំ ។ បណ្ឌិតោ**
**សីលសម្បន្នោ ជលំ អគ្គីវ ភាសតិ ភោគេ**
**សំហរមានស្ស ភមរស្សេវ ឥរីយតោ ។**

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

**ភោគា សន្និចយំ យន្តិ វម្មិកោវូបចីយតិ ឯវំ ភោគេ សមាហរិត្វា អលមត្តោ កុលេ គិហី ។ ចតុធា វិភជេ ភោគេ សវេ មិត្តានិ គន្ថតិ ឯកេន ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតីតិ ។**

មិត្តដែលមានឧបការៈ សំឡាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈឺឆ្អាល បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថា ជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និតស្នាល ដូចជាមាតានិងបុត្រដែលកើតពីទ្រូង ។ ផ្នែកប្រាជ្ញបរិបូរណ៍ដោយសីល តែងរុង

រឿងដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយតែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្តៀរ-កពូនដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូលបានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាង (តាំងខ្លួន) កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតំកល់ទុកនូវចំណែកទី៤ដោយក្រែងមានអន្តរាយទាំង

ឡាយ(ទៅខាងមុខ) កុលបុត្រនោះទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន[១]។

បទថា **មិត្តមានសេចក្តីស្រឡាញ់ មិនត្រេចអរក្នុងសេចក្តីវិនាសរបស់មិត្ត** សេចក្តីថា មិត្តមានសេចក្តីស្រឡាញ់ពេញចិត្ត ឃើញឬបានឮ សេចក្តីវិនាសបែបនោះ របស់បុត្រភរិយា ឬរបស់បរិវារជន ព្រោះសេចក្តីវិនាស គឺ ព្រោះសេចក្តីមិនចម្រើនរបស់មិត្ត រមែងមិនត្រេចអរ គឺ មិនពេញចិត្ត ។ បទថា **ដោយសេចក្តីចម្រើន** សេចក្តីថា កល្យាណមិត្ត ប្រាថ្នាឃើញ ឬបានឮ

---

[១] ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វីៗ ក៏ប្រាប់ថារបស់នោះ ខូចនេះបាត់នោះជាដើម ។

សេចក្តីសម្បូរណ៍របស់ស្រូវជាដើម ឬការបានភាពជាធំ ព្រោះសេចក្តីចម្រើនរបស់សំឡាញ់បែបនោះ រមែងត្រេកអរពេញចិត្ត ។ បទថា **ហាមអ្នកដែលតិះដៀលមិត្ត** សេចក្តីថា កាលមានអ្នកនិយាយថា អ្នកឯណោះរូបអាក្រក់ មិនគួរជ្រះថ្លា មានជាតិអាក្រក់ ឬជាអ្នកទ្រុស្តសីល ដូច្នេះ កល្យាណមិត្ត រមែងហាមអ្នកដទៃ ដែលពោលតិះដៀលសំឡាញ់របស់ខ្លួន ដោយពាក្យទាំងឡាយជាដើមថា លោកកុំនិយាយយ៉ាងនេះ គេមានរូបល្អ គួរជ្រះថ្លា មានជាតិល្អ និងដល់ព្រមដោយសីល ។ បទថា **សរសើរអ្នកដែលសរសើរមិត្ត** សេចក្តីថា កាលមានអ្នក

និយាយថា អ្នកឈ្មោះឯណោះ មានរូបល្អ គួរជ្រះថ្លា មានជាតិល្អ ដល់ព្រមដោយសីល មិត្តជាទីស្រឡាញ់ រមែងសរសើរអ្នកដទៃ ដែលនិយាយសរសើរសំឡាញ់របស់ខ្លួន យ៉ាងនេះថា លោកនិយាយល្អ លោកនិយាយពាក្យយ៉ាងនេះ ល្អហើយ បុរសនេះ មានរូបល្អ គួរជ្រះថ្លា មានជាតិល្អ ដល់ព្រមហើយដោយសីល ។

បទថា **បណ្ឌិតបរិបូរណ៍ដោយសីល រមែងរុងរឿង ភ្លឺស្វាងដូចភ្លឺ** សេចក្តីថា រមែងរុងរឿងដូចភ្លើង ដែលភ្លឺលើកំពូលភ្នំក្នុងពេលយប់ ។ បទថា **កាលបុគ្គលសន្សំទ្រព្យ** សេចក្តីថា កាលបុគ្គលមិនបៀតបៀនខ្លួនខ្លះ

អ្នកដទៃខ្លះ រួបរួមភោគៈដោយធម៌ស្មើ គឺធ្វើឲ្យជាគំនរ ។ បទថា **ដូចឃ្មុំធ្វើសំបុក** សេចក្ដីថា ធ្វើភោគៈឲ្យជាគំនរធំតាមលំដាប់ ដូចសត្វឃ្មុំមិនទំលាយពណ៌ និងក្លិនរបស់ផ្កាឈើ នាំកេសរដោយមាត់ខ្លះ ដោយស្លាបទាំងពីរខ្លះ ហើយធ្វើសំបុកប្រមាណប៉ុនកង់រថដោយលំដាប់ ។ បទថា **ភោគៈទាំងឡាយរមែងដល់នូវការកពូន** សេចក្ដីថា ភោគៈទាំងឡាយរបស់គេ រមែងដល់នូវការកពូនជាគំនរ ។ យ៉ាងណា ។ ដូចដំបូកដែលកណ្ដៀលទាំងឡាយ កឡើងដោយលំដាប់ ។ ដោយហេតុនោះ លោកទើបពោលថា ដូចជាដំបូកដែលកណ្ដៀលកពូន ។

អធិប្បាយថា ភោគៈទាំងឡាយ រមែងដល់នូវការកពូនជាគំនរ ដូចដំបូកដែលកណ្ដៀល-កពូន ដូច្នោះ ។ បទថា **សមាហ-រិត្វា** សេចក្ដីថា រួបរួមហើយ ។ បទថា **ជាអ្នកអាច** សេចក្ដីថា គ្រហស្ថជាអ្នកមានសភាពសមរម្យ ឬជាអ្នកមានសមត្ថភាព ឬជាអ្នកប្រាថ្នាដើម្បីការនៅគ្រប់គ្រងផ្ទះ ។ ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់ប្រទានព្រះឱវាទ ដោយប្រការដល់អ្នកដែលនៅគ្រប់គ្រងផ្ទះ ទើបត្រាស់ពាក្យជាដើមថា កុលបុត្រអ្នកគ្រប់គ្រងផ្ទះ គប្បីចែកភោគៈទាំងឡាយ ៤ ចំណែក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **គេនោះឯងរមែងចងមិត្តទុកបាន** សេចក្តីថា អ្នកគ្រប់-គ្រងផ្ទះនោះកាលបែងចែកភោគៈយ៉ាងនេះ ឈ្មោះថា រមែងចងមិត្តទុកបាន គឺ តាំងទុកនូវការមិនបែកគ្នា ។ អ្នកដែលមានភោគៈរមែងអាចទំនាក់ទំនងមិត្តទុកបាន អ្នកក្រៅពីនោះ មិនអាច ។ បទថា **គប្បីបរិភោគភោគៈមួយចំណែក** សេចក្តីថា គប្បីបរិភោគភោគៈមួយចំណែក ។ បទថា **គប្បីប្រកប - ការងារពីរចំណែក** សេចក្តីថា គប្បីប្រកបការងារ មានកសិកម្ម និងពាណិជ្ជកម្មជាដើមពីរចំណែក ។ បទថា **គប្បីរក្សា** គឺ គប្បីរក្សាចំណែកទីបួនទុក ។ បទថា **និងមានក្នុង**

**ពេលអន្តរាយ** សេចក្តីថា ព្រោះការងារនោះ រមែងមិនប្រព្រឹត្តទៅដូចជាថ្ងៃមួយ រហូតអស់កាលរបស់ត្រកូលទាំងឡាយ ។ គ្រាខ្លះ សូម្បីអន្តរាយ ក៏រមែងកើតឡើងបាន ដោយអំណាចរាជភ័យជាដើម ។ ព្រោះដូច្នោះ ភោគៈនឹងមានក្នុងពេលអន្តរាយទាំងឡាយកើតឡើងយ៉ាងនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា អ្នកគ្រប់គ្រងផ្ទះគប្បីរក្សាចំណែកមួយទុក ដូច្នេះ ។ ក៏ក្នុងចំណែកទាំងឡាយ ៤ នេះ គប្បីរក្សាចំណែកណាៗ ទុកបំពេញកុសល ។ កាន់យកចំណែកដែលលោកពោលក្នុងបទថា **ភោគេ ភុញ្ជេយ្យ** ។ គួរកាន់យកពីចំណែកនោះ

បរិច្ចាគទានដល់ភិក្ខុទាំងឡាយខ្លះ ដល់មនុស្សកំព្រា និងអ្នកធ្វើដំណើរជាដើមខ្លះ គួរឲ្យរង្វាន់ដល់ជាងតំម្បាញ និងអ្នកកោរកាត់ជាដើមខ្លះ ។

ម្នាលគហបតីបុត្រ អរិយសាវ័ក បិទបាំងទិសទាំង ៦ ដូចម្ដេច ។ ម្នាលគហបតីបុត្រ អ្នកត្រូវដឹងទិសទាំង ៦ដូច្នេះ គឺមាតាបិតា អ្នកត្រូវដឹងថា ទិសខាងកើត១ អាចារ្យអ្នកត្រូវដឹងថា ទិសខាងត្បូង១ កូននិងប្រពន្ធ អ្នកត្រូវដឹងថា ទិសខាងលិច ១ មិត្តអាមាត្យ អ្នកត្រូវដឹងថាទិសខាងជើង១ ទាសៈនិង

កម្មករ[១០] អ្នកត្រូវដឹងថា ទិសខាងក្រោម១ សមណៈព្រាហ្មណ៍ អ្នកត្រូវដឹងថា ទិសខាងលើ ១ ។

ដោយកថាមគ្គ ត្រឹមតែប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ប្រទានព្រះឱវាទដើម្បីវៀរធម៌ដែលគួរវៀរ និងដើម្បីសេពធម៌ដែលមិនគួរសេពថាម្នាលគហបតីបុត្រ អរិយសាវ័កលះអកុសល ដោយហេតុទាំងឡាយ ៤ វៀរផ្លូវវិនាសនៃភោគៈទាំងឡាយដោយហេតុទាំងឡាយ ៦ សេពគប់មិត្ត១៦ពួកនៅគ្រប់គ្រងផ្ទះ ធ្វើការចិញ្ចឹមរក្សាភរិយា

---

[១០] ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វីៗ ក៏ប្រាប់ថារបស់នោះ ខូចនេះបាត់នោះជាដើម ។

រមែងរស់នៅដោយអាជីវៈដែលជាធម៌ រមែងរុងរឿងដូចគំនរភ្លើងក្នុងចន្លោះទេវតា និងមនុស្សទាំងឡាយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងទិស ៦ ដែលគួរនមស្ការទើបត្រាស់ពាក្យជាដើមថា ម្នាលគហបតីបុត្រ ក៏អរិយ-សាវ័កជាអ្នកបិទបាំងទិសទាំង ៦ ដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **ព្រះអរិយសាវ័កជាអ្នកបិទបាំងទិសទាំង ៦** សេចក្ដីថា ព្រះ - មានព្រះភាគទ្រង់នៅ ដូចភ័យដែលមកពីទិសទាំង ៦ រមែងមិនមកដល់ ជាដែនក្សេមប្រាសចាកភ័យ ទើបត្រាស់ថា អរិយសាវកជាអ្នកបិទបាំងទិសទាំង ៦ ដូច្នេះ ។

ក្នុងបទទាំងឡាយជាដើមថា **មាតាបិតាជាទិសខាងកើត** ដូច្នេះ គឺគប្បីជ្រាបថា មាតាបិតាជាទិសខាងកើតព្រោះជាអ្នកមានឧបការៈមុន, អាចារ្យជាទិសខាងត្បូង ព្រោះជាអ្នកគួរដល់ទក្ខិណា, បុត្តភរិយាជាទិសខាងលិច ដោយអំណាចជាប់តាមមកជាខាងក្រោយ, មិត្តសម្លាញ់ជាទិសខាងជើង ព្រោះសូម្បីកុលបុត្រនោះអាស្រ័យមិត្ត និងសម្លាញ់ទើបឆ្លងផុតទុក្ខពិសេសនោះៗ, ទាសៈ និងកម្មករ ជាទិសខាងក្រោម ដោយអំណាចតាំងនៅទៀបជើង, សមណព្រាហ្មណ៍ជាទិសខាងលើ ព្រោះភាពជាអ្នកតាំង

នៅក្នុងខាងលើ ដោយគុណធម៌ទាំងឡាយ ។

ម្នាលគហបតីបុត្រ មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបំរុង ដោយស្ថានទាំង - ឡាយ ៥យ៉ាង គឺត្រូវតាំងចិត្តថា អាត្មាអញមាតាបិតាបានចិញ្ចឹមរក្សាមកហើយនឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀតឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរ- លោកហើយ ១ ។ ម្នាលគហបតីបុត្រ មាតាបិតាជាទិសខាងកើតដែលកូនទំនុកបំរុ

ងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែង អនុគ្រោះកូន ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះ គឺ ហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្តឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១។ ម្នាលគហបតីបុត្រ មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបំរុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន ៥យ៉ាងនេះទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេមឥតមានភយន្តរាយយ៉ាងនេះ ។

បទថា **លោកចិញ្ចឹមយើងមក យើងនឹងចិញ្ចឹមលោកវិញ** សេចក្តីថា អាត្មាអញ ដែលមាតាបិតាឲ្យផឹកទឹកដោះ ញ៉ាំងដៃនិងជើងឲ្យចម្រើន បីតសម្បោរឲ្យ ស្អិតស្អាងឲ្យចិញ្ចឹមរក្សានិងផ្គត់ផ្គង់ អាត្មាអញ នឹងចិញ្ចឹមមាតាបិតាទាំងនោះ ដែលមានវ័យចាស់ ដោយការលាងជើង ងូតទឹក ឲ្យបបរនិងបាយជាដើម ។ បទថា **យើងនឹងធ្វើកិច្ចរបស់មាតាបិតា** សេចក្តីថា យើងនឹងវៀរការងាររបស់ខ្លួន ទៅធ្វើកិច្ចដែលកើតឡើងក្នុងរាជសម្នាក់ជាដើមដល់មាតាបិតា ។ បទថា **យើងនឹងរក្សាវង្សត្រកូល** សេចក្តីថា បុត្រមិនធ្វើឲ្យវត្ថុប្រាក់និងមាសជាដើមដែលជារបស់

មាតាបិតាឲ្យវិនាស សូម្បីរក្សា ក៏ឈ្មោះថា រក្សាវង្សត្រកូល បុត្រធ្វើឲ្យមាតាបិតាវិនាស ចាកវង្ស ដែលប្រកបដោយអធម៌សូម្បីឲ្យតាំងនៅក្នុងវង្សដែលប្រកបដោយធម៌ មិនចូលទៅហាមសលាកភត្តជាដើម ដែលមកដល់ហើយដោយវង្សត្រកូល សូម្បីឲ្យប្រ-ព្រឹត្តទៅក៏ឈ្មោះថា រក្សាវង្សត្រកូល ។ លោកពោលសំដៅដល់បទនេះ ទើបពោលថា អាត្មាអញនឹងរក្សាវង្សត្រកូល ដូច្នេះ ។ បទថា **យើងនឹងបដិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមត៌ក** សេចក្តីថា មាតាបិតាទៅដល់រោងសាលា ធ្វើទារកដែលមិនប្រព្រឹត្តតាមឱវាទរបស់ខ្លួនដែលបដិបត្តិខុសមិនឲ្យកាន់

យកថាជាបុត្រ, បុត្រទាំងនោះ ក៏ជាអ្នកមិនសមគួរទទួល មត៌កតែមាតាបិតារមែងធ្វើបុត្រដែលប្រព្រឹត្តតាមឱវាទឲ្យជាម្ចាស់ទ្រព្យដែលមាននៅក្នុងត្រកូលលោកពោលថា យើងនឹងប្រតិបត្តិខ្លួនឲ្យសមគួរទទួលមត៌កបានដោយបំណងថា យើងនឹងប្រព្រឹត្តយ៉ាងនោះ ដូច្នេះ ។ បទថា **កាលមាតាបិតាធ្វើកាលកិរិយាទៅហើយ នឹងធ្វើបុណ្យឧទ្ទិសឲ្យលោក**សេចក្តីថាអាត្មាអញនឹងធ្វើទានឧទ្ទិសចំណែកបុណ្យឲ្យដល់មាតាបិតាទាំងនោះ ហើយនឹងផ្តើមធ្វើទាន ឧទ្ទិសឲ្យតាំងពីថ្ងៃទីបី ។

បទថា **មាតាបិតា ហាមបុត្តពីសេចក្ដីអាក្រក់** សេចក្ដីថា មាតាបិតាពោលដល់ទោសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខនៃបាណាតិបាតជាដើមហើយហាមថា កូនអើយកុំធ្វើកម្មបែបនេះឡើយ ដូច្នេះ ស្ដីបន្ទោសបុត្រ ដែលធ្វើហើយ ។ បទថា **ឲ្យតាំងនៅសេចក្ដីល្អ** សេចក្ដីថា មាតាបិតាសូម្បីឲ្យតម្លៃឈ្នួលដូចអនាថបិណ្ឌិកសេដ្ឋីក៏នៅតែឲ្យបុត្រតាំងនៅក្នុងការសមាទានសីលជាដើម ។ បទថា **ឲ្យរៀនសិល្បៈ** សេចក្ដីថា មាតាបិតាដឹងដល់បុត្ត ដែលតាំងនៅក្នុងឱវាទរបស់ខ្លួនហើយញុំាងបុត្រឲ្យសិក្សាសិល្បៈ មានការរាប់លេខដែលខ្ពស់ៗជា-

ដើម ដែលប្រព្រឹត្តទៅតាមវង្សត្រកូល ។ បទថា **រកភរិយាដែលសមគួរឲ្យ** គឺសមគួរដោយត្រកូល មានសីលនិងរូបជាដើម ។ បទថា **ប្រគល់ទ្រព្យឲ្យក្នុងសម័យ** សេចក្ដីថា ឲ្យទ្រព្យក្នុងសម័យដែលគួរ ។ ក្នុងបទនោះ សម័យមាន ២ យ៉ាង គឺ និច្ចសម័យ១ កាលសម័យ១ ។ មាតាបិតាឲ្យដោយពាក្យថា ចូរកូនប្រញាប់ប្រញាល់ កាន់យកវត្ថុដែលគួរកាន់យកនេះ, នេះចូរជាទ្រព្យសម្រាប់ចំណាយរបស់កូន,

កូនចូរធ្វើកុសលដោយទ្រព្យសម្រាប់ចំណាយនេះ ដូច្នេះ ឈ្មោះថា ឲ្យក្នុងនិច្ចសម័យឲ្យជានិច្ច ។ មាតាបិតា រមែងឲ្យក្នុងចាត់

ចែង ការងារជាដើមឈ្មោះថា ឲ្យក្នុងកាលសម័យ ។ ម្យ៉ាងទៀត មាតាបិតាសូម្បីឲ្យដោយពាក្យថា កូនចូរធ្វើកុសលដោយទ្រព្យនេះ ដល់បុត្រដែលដេកលើគ្រែធ្វើមរណៈក្នុងគ្រាចុងក្រោយ ឈ្មោះថា ឲ្យក្នុងសម័យ ។

បទថា **ទិសខាងមុខនោះ ដែលបុត្តបិទបាំងហើយ** សេចក្ដីថា ទិសខាងមុខ ដែលបុត្របិទបាំងហើយ ដោយភ័យដែលគប្បីមកអំពីទិសខាងកើត រមែងមិនមកដល់ ។ ក៏ប្រើបុត្រទាំងឡាយគប្បីបតិបត្តិខុស មាតាបិតាជាអ្នកបតិបត្តិប្រពៃ ដោយការចិញ្ចឹមជាដើម តាំងពីរនៅជាកម្លោះទារកទាំងនោះ

ជាអ្នកមិនសមគួរដល់មាតាបិតា ព្រោះ
ដូច្នោះភ័យនោះគប្បីមកដល់ ។ បុត្រទាំង-
ឡាយជាអ្នកបតិបត្តិប្រពៃ មាតាបិតាជាអ្នក
បតិបត្តិខុសមាតាបិតាក៏មិនសមគួរដល់បុត្រ
ទាំងឡាយ ដូច្នោះភ័យនេះគប្បីមកដល់ ។
កាលទាំងពីរបតិបត្តិខុសក៏មានភ័យទាំងពីរ
យ៉ាង ។ កាលទាំងពីរបតិបត្តិត្រូវ ក៏មិនមាន
ភ័យទាំងអស់ ។ ដោយហេតុនោះលោក
ទើបពោលថា ទិសខាងកើតនោះដែលកូន
បិទបាំងឲ្យក្សេមមិនឲ្យមានភ័យ ដូច្នេះ ។
លុះព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ
បានត្រាស់ដល់សិង្គាលកៈថា ម្នាលគហប-
តីបុត្របិតារបស់អ្នកមិនបានឲ្យអ្នកនមស្ការ

ទិសខាងមុខដែលលោកសន្មត តែបិតារបស់អ្នក ធ្វើមាតាបិតាឲ្យដូចជាទិសខាងមុខហើយឲ្យអ្នកនមស្ការបិតារបស់អ្នក ពោលដល់ទិសខាងមុខយ៉ាងនេះ មិនមែនយ៉ាងដទៃ ។

## ទិសទាំង ៦ពោលអំពីទិសខាងត្បូង

ម្នាលគហបតីបុត្រ អាចារ្យជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន ៥យ៉ាង គឺដោយការក្រោកឡើងទទួល១ ដោយការគាល់បំរើ១ ដោយការជឿស្តាប់ឱវាទ១ ដោយការបំរើតូច១ (មានឲ្យទឹកលុបមុខនិងឈើស្ទន់ជាដើម) ១

ដោយការរៀនសិល្បសាស្រ្តដោយគោរព ១ ។ ម្នាលគហបតីបុត្រ អាចារ្យជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងវិញ គឺដឹកនាំល្អ ១ ឲ្យរៀនល្អ ១ ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងសិល្បសាស្រ្តសព្វគ្រប់ ១ តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ ១ ធ្វើសេចក្តីការពារក្នុងទិសទាំងឡាយ ១ ។ ម្នាលគហ-បតីបុត្រ ពួកអាចារ្យជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយរមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងនេះ ទិសខាងត្បូងនោះ ដែល

សិស្សបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

បទថា **ដោយការក្រោកឡើង** គឺ ដោយក្រោកឡើងអំពីទីអង្គុយ ។ ពិតហើយ សិស្សឃើញអាចារ្យមកអំពីចម្ងាយ ក្រោកអំពីទីអង្គុយ ធ្វើការទទួលរបស់អំពីដៃ ក្រាលអាសនៈឲ្យអាចារ្យអង្គុយហើយគប្បីធ្វើការបក់ លាងជើង ច្របាច់ជើងជាដើម នោះ លោកពោលសំដៅយក បទថា **ឧដ្ឋា-នេន** ដូច្នេះ ។ បទថា **ដោយការទទួលបំរើ** សេចក្ដីថា ដោយចូរទៅបម្រើ ១ ថ្ងៃ ៣ដង ។ តែដែលពិតក៏គួរទៅដោយការរៀន

សិល្បៈ។ បទថា **ដោយការជឿស្តាប់**សេចក្តីថា ក៏សិស្សកាលមិនជឿមិនស្តាប់តាម រមែងមិនសម្រេចគុណវិសេស ។ បទថា **ដោយការប្រតិបត្តិ** គឺដោយការប្រតិបត្តិ បន្តិចបន្តួច មិនហួសពីសមត្ថភាព ។ ពិត ណាស់ សិស្សគួរក្រោកឡើងអំពីព្រឹក ឲ្យ ទឹកខ្ពុរមាត់ ឈើស្ទន់ សូម្បីក្នុងវេលាអាហារ ក៏កាន់យកទឹកផឹកទៅឲ្យ ហើយធ្វើការបម្រើ រួចស្រេចហើយ គួរត្រឡប់មកបាន គួរបោក សំពត់ដែលសៅហ្មង គួរតាំងទឹកងូតក្នុង វេលាល្ងាច គួរឧបដ្ឋាកក្នុងវេលាលោកមិន សប្បាយ ។ សូម្បីបព្វជិតក៏គួរធ្វើអន្តេវាសិក វត្តគ្រប់យ៉ាង ។ នេះលោកសំដៅយកបទថា

បារិចរិយាយ ។ បទថា **ការរៀនសិល្បៈដោយគោរព** សេចក្តីថា ការរៀនបន្តិចបន្តួចហើយទន្ទេញច្រើនៗ ដងសូម្បីមួយបទក៏គួររៀនឲ្យដឹងពិតឈ្មោះថារៀនដោយសេចក្តីគោរព ។

បទថា **ណែនាំល្អ** សេចក្តីថា អាចារ្យទាំងឡាយរមែងឲ្យសិស្សសិក្សា គឺ ណែនាំមារយាទនេះថា អ្នកគួរអង្គុយយ៉ាងនេះគួរឈរយ៉ាងនេះគួរទំពារយ៉ាងនេះ គួរបរិភោគយ៉ាងនេះគួរវៀរមិត្តអាក្រក់ គួរសេពគប់មិត្តល្អ ដូច្នេះ ។ បទថា **ឲ្យរៀនល្អ** សេចក្តីថា អាចារ្យទាំងឡាយជម្រះអត្ថ និងព្យញ្ជនៈបង្ហាញប្រយោគហើយឲ្យសិស្សរៀនដោយ

អាការដែលសិស្សបានល្អ ។ បទថា **លើកសរសើរឲ្យប្រាកដក្នុងពួកមិត្ត** សេចក្តីថា អាចារ្យទាំងឡាយពោលដល់គុណរបស់សិ-ស្សយ៉ាងនេះថា សិស្សរបស់យើងម្នាក់នេះឆ្លាតជាពហុស្សូត ស្មើនឹងយើងពួកលោកគប្បីរក្សាសិស្សនេះទុក ហើយឲ្យសិស្សប្រាកដក្នុងពួកមិត្តទាំងឡាយ ។ បទថា **ធ្វើ-ការការពារក្នុងទិសទាំងឡាយ** សេចក្តីថា អាចារ្យរមែងធ្វើការការពារសិស្សក្នុងទិសទាំងពួង ដោយឲ្យសិក្សាសិល្បៈ ។ ព្រោះថាលាភសក្ការៈរមែងកើតដល់អ្នករៀនសិល្បៈ ក្នុងទិសដែលទៅសម្តែងសិល្បៈ លាភសក្ការៈនោះបានឈ្មោះថាអាចារ្យធ្វើ

ហើយ ។ មហាជនសូម្បីកាលនឹងពោល ដល់គុណរបស់សិស្សនោះ រមែងពោលដល់ គុណរបស់អាចារ្យមុនដោយពិតថាសិស្ស របស់លោកនេះជាសិស្សដែលលាងជើង អាចារ្យហើយ ដូច្នេះ ។ លាភរមែងកើត ឡើងដល់សិស្សនោះ សូម្បីប្រមាណដល់ ព្រហ្មលោក ក៏ជារបស់អាចារ្យនុ៎ះឯង ។ម្យ៉ាងទៀត ចោរទាំងឡាយក្នុងព្រៃ រមែង មិនឃើញ អមនុស្សក្តី ពស់ជាដើមក្តី រមែង មិនបៀតបៀន សិស្សណាអ្នកចង់បានវិជ្ជា ដើរទៅ អាចារ្យសូម្បី ឲ្យសិស្សនោះសិក្សាក៏ ឈ្មោះថា រមែងធ្វើសេចក្តីការពារក្នុងទិស ទាំងឡាយ ។ អាចារ្យទាំងឡាយ សូម្បី

លើកតម្កើនសិស្សយ៉ាងនេះថា សិស្សរបស់យើងនៅក្នុងទិសនេះ មិនមានសេចក្ដីផ្សេងគ្នាក្នុងសិល្បៈនេះ របស់សិស្ស និងរបស់យើង ពួកលោកចូរទៅសួរសិស្សនោះចុះ ដល់មនុស្សអ្នកកើតការសង្ស័យពីទិសដែលសិស្សនោះទៅហើយមករកខ្លួន ក៏ឈ្មោះថា រមែងធ្វើការការពារ ព្រោះលាភសក្ការៈកើតឡើងដល់សិស្សក្នុងទីនោះ អធិប្បាយថា រមែងធ្វើឲ្យជាទីពឹង ។ បទថាដ៏សេសក្នុងរឿងនេះ គប្បីប្រកបដោយន័យមុននោះឯង ។

ម្នាលគហបតីបុត្រ ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំង-

ឡាយ ៥ យ៉ាង គឺដោយការរាប់អានជាភរិយាពេញទី១ ដោយមិនមើលងាយ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត១ ដោយប្រគល់ឲ្យជាធំ(ក្នុងការផ្ទះ)១ ដោយការឲ្យគ្រឿងតែងខ្លួន១ ។ ម្នាលគហបតីបុត្រ ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯង ហើយរមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥យ៉ាងវិញ គឺចាត់ចែងការងារដោយល្អ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ១ មិនប្រព្រឹត្តក្បត់ចិត្ត១ ថែទាំទ្រព្យដែលស្វាមីរកបានមក១ ឈ្លាសមិនខ្ជិលច្រអូស ក្នុងកិច្ចការសព្វគ្រប់១ ។ ម្នាលគហបតីបុត្រ

ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯង ហើយរមែងអនុគ្រោះស្វាមីដោយស្ថាន ៥យ៉ាងនេះ ទិសខាងលិចនោះ ដែលស្វាមីបិទបាំងហើយ ជាទិសមានសេចក្តីក្សេមផតមានភយន្តរាយយ៉ាងនេះ ។

គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី៣៖

បទថា **ដោយការលើកសរសើរ** សេចក្តីថា ដោយពោលពាក្យលើកតម្កើងយ៉ាងនេះថា នាងទេវ នាងតិស្សា ដូច្នេះ ។ បទថា **ដោយមិនមើលងាយ** សេចក្តីថា ដោយមិនពោលមើលងាយមើលថោក ដូចវាយធ្វើ

បាបហើយនិយាយចំពោះទាសៈនិងកម្មករ ជាដើម ដូច្នេះ ។ បទថា **ដោយមិនប្រព្រឹត្តក្បត់ចិត្ត** សេចក្តីថា ស្វាមី លះបង់ភរិយាហើយ ទៅរីករាយនឹងស្រីដទៃ ឈ្មោះថា **ប្រព្រឹត្តក្បត់ចិត្តភរិយា ដោយមិនធ្វើយ៉ាងនោះ** ។ បទថា **ដោយប្រគល់ភាពជាធំឲ្យ** សេចក្តីថា ពិតហើយស្រ្តីទាំងឡាយបានអាភរណៈសូម្បីដូចគ្រឿងប្រដាប់មហាលតា កាលមិនបានចាត់ចែងអាហាររមែងក្រោធ កាលស្វាមីដាក់វែកក្នុងដៃហើយពោលថានាងចូរធ្វើតាមចិត្តរបស់នាងចុះ ដូច្នេះ ហើយប្រគល់ផ្ទះបាយឲ្យ ឈ្មោះថាប្រគល់ភាពជាធំឲ្យទាំងអស់ អធិប្បាយថា ដោយធ្វើយ៉ាង

នោះ ។ បទថា **ប្រគល់គ្រឿងប្រដាប់ឲ្យ** សេចក្តីថា ដោយប្រគល់គ្រឿងប្រដាប់តាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

បទថា **ភរិយាចាត់ចែងការងារល្អ** សេចក្តីថា ភរិយាមិនលះបង់វេលាដាំបាយ ដាំបបរ និងស្លជាដើម ហើយចាត់ចែងការងារឲ្យល្អ ដោយការធ្វើសេចក្តីល្អដល់ស្វាមីនោះៗ ។

បទថា**សង្គ្រោះបរិជន** សេចក្តីថាសង្គ្រោះបរិជនដោយសេចក្តីរាប់អានជាដើម និងដោយការបញ្ជូនដំណឹងជាដើម ។ ជនជាញាតិរបស់ស្វាមីនិងរបស់ខ្លួន ឈ្មោះថាបរិជនក្នុងទីនេះ ។ បទថា មិនប្រព្រឹត្តក្បត់

ចិត្តស្វាមី សេចក្តីថាមិនបោះបង់ស្វាមីចោល ហើយប្រាថ្នាប្រុសដទៃសូម្បីដោយចិត្ត ។ បទថា **រក្សាទ្រព្យដែលស្វាមីរកមកបាន** សេចក្តីថា ទ្រព្យដែលស្វាមីធ្វើកសិកម្ម និង ធ្វើពាណិជ្ជកម្មជាដើមហើយនាំមករក្សាទុក ។ បទថា **ជាអ្នកឈ្លាស** សេចក្តីថា ជាអ្នក ពិចារណាល្អិតល្អន់ ក្នុងការចាត់ចែងបាយ យាគូ និងភត្តជាដើម ។ មិនខ្ជិលច្រអូស សេចក្តីថាមិនខ្ជិល ភរិយាមិនដូចជាស្រីពួក ដទៃ ដែលខ្ជិលច្រអូសអង្គុយនៅនឹងកន្លែង ដែលខ្លួនអង្គុយ ឈរនៅនឹងទីដែលខ្លួនឈរ ដូច្នោះ រមែងញុំាងកិច្ចទាំងពួងឲ្យសម្រេច

ដោយចិត្តដ៏ទូលាយ ។ គប្បីប្រកបបទ ដ៏សេសក្នុងរឿងនេះ ដោយន័យមុនន៉ុះឯង ។

## ទិសទាំង ៦ពោលអំពីទិសខាងជើង

ម្នាលគហបតីបុត្រ មិត្តអាមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការឲ្យរបស់ ១ ដោយការនិយាយតែពាក្យគាប់ចិត្ត១ ដោយការប្រព្រឹត្តឲ្យជាប្រយោជន៍ ១ ដោយការប្រព្រឹត្តខ្លួនស្មើ ១ ដោយការមិនកុហកបញ្ឆោត១ ។ ម្នាលគហបតីបុត្រមិត្តអាមាត្យជាទិសខាងជើង ដែលកុលបុត្តប្រតិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុ-

គ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ ជួយថែទាំទ្រព្យសម្បត្តិ របស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងរបស់មិត្តដែលមានភ័យ ១ មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ ១ រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ១ ។ ម្នាលគហបតីបុត្រមិត្តអាមាត្យជាទិសខាងជើង ដែលកុលបុត្តប្រ-តិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងនេះ ទិសខាងជើងនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី ៤៖

បទថា **មិនក្លែងពោលឲ្យឃ្លាតពីសេចក្តីពិត** សេចក្តីថា ដោយមិនក្លែងពោលឲ្យឃ្លាតចាកសេចក្តីពិត ដល់អ្នកដែលប្រកាន់ទុកហើយ មិនក្លែងពោលឲ្យឃ្លាតចាកសេចក្តីពិតហើយ យ៉ាងនេះថាសូម្បីឈ្មោះនេះក៏មាននៅក្នុងស្រុករបស់ពួកយើង សូម្បីឈ្មោះនេះ ក៏មានលោកចូរទទួលយកចុះ ។

បទថា **រាប់អានរហូតដល់វង្សរបស់មិត្ត** សេចក្តីថា បុត្រធីតារបស់សម្លាញ់ ឈ្មោះប្រជា ក៏បុត្រធីតារបស់បុត្រធីតាទាំងនោះជាក្មួយនិងជាចៅ ឈ្មោះថា ប្រជាដទៃៗ

រមែងបូជា រមែងត្រេកអរ រមែងរាប់អានពួកគេ ធ្វើការមង្គលជាដើមដល់ពួកគេ ក្នុងការធ្វើពិធីមង្គលជាដើម ។ បទដ៏សេសក្នុងរឿងនេះគប្បីប្រកបដោយន័យមុននោះឯង ។

ម្នាលគហបតីបុត្រ ទាសៈនិងកម្មករ ជាទិសខាងក្រោម ថៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន ៥យ៉ាង គឺដោយការចាត់ចែងការងារសមគួរតាមកំលាំង១ ដោយការឲ្យនូវភត្តាហារនឹងថ្លៃឈ្នួល១ ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់១ ដោយការចែករំលែកនូវរបស់មានរស់ត្រកាលចម្លែក១ ដោយការឲ្យឈប់សម្រាកក្នុងសម័យគួរ១ ។ ម្នាលគហបតីបុត្រ ទាសៈនិងកម្មករ ជា

ទិសខាងក្រោម ថៅហ្វាយនាយទំនុកបម្រុង ដោយស្ថាន ៥យ៉ាងហើយ រមែងអនុគ្រោះ ថៅហ្វាយនាយដោយស្ថាន ៥យ៉ាង គឺ ក្រោកឡើងធ្វើការងារមុន ថៅហ្វាយនាយ១ ឈប់ធ្វើការងារក្រោយថៅហ្វាយនាយ១ កាន់យកតែរបស់ដែលថៅហ្វាយនាយឲ្យ១ ធ្វើការងាររបស់ថៅហ្វាយនាយ ដោយយក ចិត្តទុកដាក់១ នាំកិត្តិគុណរបស់ ថៅហ្វាយ នាយទៅថ្លែងក្នុងទីនោះៗ១ ។ ម្នាលគហ-បតីបុត្រ ទាសៈនិងកម្មករ ជាទិសខាង ក្រោម ដែលថៅហ្វាយនាយទំនុកបម្រុង ដោយស្ថាន ៥យ៉ាងនេះឯងហើយ រមែង អនុគ្រោះថៅហ្វាយនាយដោយស្ថាន ៥

យ៉ាងនេះ ទិសខាងក្រោមនុ៎ះ ដែលថៅហ្វាយនាយបានបិទបាំងហើយជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

បទថា **ចាត់ចែងការងារដោយកម្លាំង** សេចក្ដីថា ដោយមិនឲ្យមនុស្សចាស់ធ្វើការងាររបស់មនុស្សកម្លោះ ឬមិនឲ្យមនុស្សកម្លោះធ្វើការងាររបស់មនុស្សចាស់ មិនឲ្យបុរសធ្វើការងារដែលស្រីធ្វើ ឬមិនឲ្យស្រីធ្វើការងារដែលបុរសធ្វើ ហើយចាត់ការងារតាមកម្លាំងរបស់បុគ្គលនោះៗឯង ។

បទថា **ឲ្យអាហារ និងរង្វាន់** សេចក្ដីថា ដោយកំណត់សេចក្ដីសមគួររបស់បុគ្គល នោះៗថា បុគ្គលនេះនៅតូច អ្នកនេះនៅរួម គ្នាមកដូច្នេះ ហើយឲ្យអាហារ និងឲ្យតម្លៃ (មាសប្រាក់)ចាយវាយ ។ បទថា **ដោយរក្សាក្នុងវេលាឈឺ** សេចក្ដីថា ដោយមិនឲ្យ ធ្វើការងារក្នុងវេលាមិនសប្បាយ ហើយឲ្យ ថ្នាំ ធ្វើឲ្យសប្បាយជាដើម ហើយថែរក្សា ។ បទថា **ចែករបស់មានរសប្លែកៗ ឲ្យបរិភោគ** សេចក្ដីថា កាលបានរបស់មានរសឆ្ងាញ់ ប្លែកៗ ហើយ មិនបរិភោគដោយខ្លួនឯង ទាំងអស់ ចែកឲ្យទាសៈ និងកម្មករទាំងនោះ ។

បទថា **ដោយឈប់សម្រាកក្នុងសម័យ** សេចក្តីថា ដោយឲ្យឈប់សម្រាកក្នុងនិច្ចសម័យ និងកាលសម័យ ។ ទាសៈ និងកម្មករធ្វើការងាររហូតអស់មួយថ្ងៃ រមែងនឿយហត់ ព្រោះដូច្នោះ ការដឹងវេលាហើយឲ្យឈប់សម្រាកដោយប្រការដែលទាសៈ និងកម្មករមិននឿយហត់ ឈ្មោះថាឲ្យឈប់សម្រាកក្នុងនិច្ចសម័យ ។

ការឲ្យរបស់ទំពារ និងរបស់បរិភោគជាដើម ក្នុងថ្ងៃមានមហោស្រព នក្ខត្តឫក្ស និងលេងកីឡាជាដើម ហើយឲ្យឈប់សម្រាក ឈ្មោះថា ឲ្យឈប់សម្រាកក្នុងកាលសម័យ ។

បទថា **កាន់យកតែរបស់ដែលថៅហ្វាយឲ្យ** សេចក្តីថា មិនកាន់យកអ្វីៗ ដូចចោរ កាន់យកតែរបស់ដែលនាយថៅហ្វាយឲ្យ ប៉ុណ្ណោះ ។ បទថា **ធ្វើការងារឲ្យល្អឡើង** សេចក្តីថា មិនសម្លឹងទោសថា រឿងអ្វីដែល យើងនឹងធ្វើការងារឲ្យដល់គេ យើងមិន ឃើញបានអ្វីៗ ឡើយ ហើយមានចិត្តត្រេក-អរ ធ្វើការងារ ជាអ្នកធ្វើការងារដែលធ្វើល្អ ហើយ ។ បទថា **នាំគុណរបស់ថៅហ្វាយទៅសរសើរ** សេចក្តីថា កាលដល់គ្រាសន្ទនាគ្នា ត្រង់កណ្តាលបរិស័ទ នាំគុណរបស់នាយ ថៅហ្វាយទៅសរសើរថា មិនមានអ្នកណា ដូចនឹងនាយថៅហ្វាយរបស់យើង យើងមិន

ដឹងថា សូម្បីភាពជាទាសៈរបស់ខ្លួន មិនដឹង សេចក្ដីដែលលោកទាំងនោះ ជាចៅហ្វាយ អនុគ្រោះដល់ពួកយើងយ៉ាងនេះ ។ បទ ដ៏សេសសូម្បីក្នុងរឿងនេះ គប្បីប្រកបដោយ ន័យមុននោះឯង ។

ម្នាលគហបតីបុត្រ សមណព្រាហ្មណ៍ជា ទិសខាងលើ កុលបុត្តត្រូវផ្គត់ផ្គង់ដោយ ស្ថាន ៥ យ៉ាង គឺដោយកាយកម្មប្រកប ដោយមេត្តា ១ ដោយវចីកម្មប្រកបដោយ មេត្តា ១ ដោយមនោកម្មប្រកបដោយមេត្តា ១ ជាអ្នកមិនបិទទ្វា[១១]ផ្ទះ ដោយកិរិយាឲ្យ

---

[១១] ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វីៗ ក៏ប្រាប់ថារបស់នោះ ខូច នេះបាត់នោះជាដើម ។

អាមិសទាន ១ ម្នាលគហបតីបុត្រ សមណព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្តទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ គឺ ហាមឃាត់កុលបុត្តចាកអំពើអាក្រក់ ១ ឲ្យតាំងនៅតែក្នុងអំពើល្អ ១ អនុគ្រោះដោយចិត្តដ៏ល្អ ១ ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់ស្តាប់ ១ បំភ្លឺសេចក្តីដែលមិនធ្លាប់ស្តាប់ហើយ ១ ប្រាប់ផ្លូវសួគ៌ ១ ម្នាលគហបតីបុត្រ សមណព្រាហ្មណ៍ជាទិសខាងលើ កុលបុត្តត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ នេះ ទិសខាងលើដែលកុលបុត្ត

បានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភ័យអន្តរាយយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់បានសំដែងសេចក្ដីនេះ លុះព្រះសុគតជាសាស្ដាសំដែងសេចក្ដីនេះហើយ ទើបទ្រង់សំដែងពាក្យគាថាព័ន្ធតទៅទៀតថា៖

**មាតាបិតា ទិសា បុព្វា អាចរិយា ទក្ខិណា**
**ទិសា បុត្តទារា ទិសា បច្ឆា មិត្តាមច្ចា ច ឧត្តរា**
**ទាស កម្មករា ហេដ្ឋា ឧទ្ធំ**
**សមណព្រាហ្មណា ឯតា ទិសា នមស្សេយ្យ**
**អលមត្តោ កុលេ គិហី ។ បណ្ឌិតោ**
**សីលសម្បន្នោ សណ្ហោ ច បដិភាណវា**
**និវាតវុត្តិ អត្ថទ្ធោ តាទិសោ លភតេ យសំ**

ឧដ្ឋានកោ អនលសោ អាបទាសុ ន វេធតិ
អច្ឆិទ្ទវុត្តិ មេធាវី តាទិសោ លភតេ សយំ ។
សង្គាហកោ មិត្តករោ វទញ្ញូ វីតមច្ឆរោ នេតា
វិនេតា អនុនេតា តាទិសោ លភតេ សយំ ។
ទានញ្ច បិយវជ្ជញ្ច អត្ថចរិយា ច យា ឥធ
សមានតា ច ធម្មេសុ តត្ថ តត្ថ យថារហំ ។
ឯតេ ខោ សង្គហា លោកេ រថស្សាណីវ
យាយតោ ឯតេ ច សង្គហា នាស្សុ ន មាតា
បុត្តការណា លភេថ មានំ បូជំ បិតា វា
បុត្តការណា ។ យស្មា ច សង្គហា ឯតេ
សមបេក្ខន្តិ បណ្ឌិតា តស្មា មហត្តំ បប្បោន្តិ
បាសំសា ច ភវន្តិ តេតិ ។

មាតាបិតា ជាទិសខាងកើត អាចារ្យ ជាទិសខាងត្បូង កូនប្រពន្ធ ជាទិសខាងលិច មិត្តអាមាត្យ ជាទិសខាងជើង ទាសៈនិងកម្មករ ជាទិសខាងក្រោម សមណព្រាហ្ម-ណ៍ ជាទិសខាងលើ គ្រហស្ថក្នុងត្រកូលដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ។ បណ្ឌិតបរិបូណ៌ ដោយសីល មានវាចាដ៏ពិរោះ មានប្រាជ្ញាវៃមានកិរិយាប្រព្រឹត្តិឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះ រមែងបានយស បុគ្គលមានព្យាយាមរៀសរវៃ មិនខ្ជិលច្រអូស រមែងមិនញាប់ញ័រក្នុងអន្តរាយទាំងឡាយ បុគ្គលមានកិរិយាប្រព្រឹត្តិឥត

ចន្លោះ មានប្រាជ្ញាវាងវៃ បុគ្គលមានសភាពដូច្នោះ រមែងមានយស ។ បុគ្គលមានសេចក្តី សង្គ្រោះជាអ្នកចងមិត្ត ជាអ្នកដឹងដំណើរពាក្យ ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ជាអ្នកដឹកនាំពន្យល់ការណ៍ផ្សេងៗ ជាអ្នកណែនាំរឿយៗ បុគ្គលមានសភាពដូច្នោះរមែងបានយស ។ ទាន១ ពាក្យពិរោះ១ សេចក្តីប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ១ ភាវៈជាអ្នកមានចិត្តស្មើ ក្នុងធម៌ទាំងឡាយ នឹងក្នុងបុគ្គលនោះៗតាមសមគួរ១ ។ សង្គហធម៌ទាំងនេះ(មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន) ដូចជារថមានប្រែកទប់ទើបប្រព្រឹត្តទៅបានដូច្នោះ

ឯង បើសង្គហធម៌ទាំងនេះមិនមានហើយ មាតាក្តី បិតាក្តី ក៏មានបាននូវសេចក្តីរាប់អាននិងការបូជា អំពីកិច្ចដែលកូនត្រូវធ្វើ ។ ព្រោះហេតុតែអ្នកប្រាជ្ញទាំងឡាយ សម្លឹងឃើញសង្គហធម៌ទាំងនោះដោយប្រពៃ ហេតុនោះបានជាលោកដល់នូវភាវៈជាធំផង គួរគេសរសើរផង ។

## ទិសទាំង ៦ និយាយអំពីទិសខាងលើ

លោកពោលមេត្តាកាយកម្មជាដើម ដែលកុលបុត្រ ចូលទៅតាំងមេត្តាចិត្តធ្វើហើយក្នុងបទទាំងឡាយជាដើមថា ដោយកាយ-កម្មប្រកបដោយមេត្តា ដូច្នេះ ។ ក្នុងបទទាំង

នោះការទៅវត្តដោយគិតថា យើងនឹងនិមន្ត ភិក្ខុទាំងឡាយ ការកាន់ធម្មក្រក (តម្រង់) និងការធ្វើមានការគក់ខ្នង និងច្រូបាច់ជើង ជាដើម ឈ្មោះថា **កាយកម្មប្រកបដោយមេត្តា** ។ ការឃើញភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាត ហើយពោលពាក្យជាដើមថា ពួកលោកចូរថ្វាយបបរ ពួកលោកចូរថ្វាយបាយ ដោយសេចក្តី គោរព ដូច្នេះ ការឲ្យសាធុការហើយ ស្តាប់ធម៌ និងការធ្វើការបដិសណ្ឋារៈជាដើម ដោយសេចក្តីគោរព ឈ្មោះថា **វចីកម្មប្រកបដោយមេត្តា** ។ ការគិតយ៉ាងនេះថា ព្រះថេរៈអ្នកចូលទៅកាន់ត្រកូលរបស់ពួកយើង ចូរជាអ្នកមិនមាន

ពៀរ ចូរជាអ្នកមិនបៀតបៀនគ្នាចុះ ឈ្មោះថា **មនោកម្មប្រកបដោយមេត្តា** ។ បទថា **អនាវដទ្វារតាយ** ប្រែថាដោយភាពជាអ្នកមិនបិទទ្វារ ។ ក្នុងបទនោះអធិប្បាយថា កុលបុត្រសូម្បីបើកទ្វារទាំងអស់ មិនឲ្យមិនទទួលអ្នកមានសីលទាំងឡាយ ក៏ឈ្មោះថា **ជាអ្នកបិទទ្វារនុ៎ះឯង** ។ ក៏ប៉ុន្តែថា កុលបុត្រសូម្បីបិទទ្វារទាំងអស់ ឲ្យទទួលអ្នកមានសីលទាំងនោះ ក៏ឈ្មោះថា ជាអ្នកបើកទ្វារនោះឯង ។ កាលអ្នកមានសីលមកដល់ទ្វារផ្ទះ មិនគួរពោល វត្ថុដែលមានហើយ ថាមិនមាន ហើយថ្វាយ យ៉ាងនេះឈ្មោះថា ភាពជាអ្នកមិនបិទទ្វារ ។ បទថា **ដោយអាមិស** -

**ទានរឿយៗ** អធិប្បាយថា របស់ដែលគួរបរិភោគ មុនភត្តាហារ ឈ្មោះថា **អាមិស** ព្រោះដូច្នោះ ដោយការថ្វាយបាយ យាគូ និង ភត្តដល់អ្នកមានសីលទាំងឡាយ ដូច្នោះ ។

បទថា **អនុគ្រោះដោយចិត្តស្អាត** សេចក្តីថា ដោយផ្សាយប្រយោជន៍យ៉ាងនេះថា សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមានសេចក្តីសុខ មិនមានពៀ មិនមានរោគ កុំបៀតបៀនគ្នាចុះ ។ ម្យ៉ាងទៀត សមណព្រាហ្មណ៍ សូម្បីនាំសព្រហ្មចារីអ្នកមានសីលពួកដទៃ ហើយចូលទៅកាន់ផ្ទះរបស់ឧបដ្ឋាកទាំងឡាយ ក៏ឈ្មោះថា **អនុគ្រោះ**

**ដោយចិត្តដ៏ល្អ** ។ បទថា **ធ្វើវត្តុដែលស្ដាប់ហើយឲ្យច្បាស់លាស់** សេចក្ដីថា មានវត្ថុណាដែលកុលបុត្រទាំងនោះ ស្ដាប់ហើយតាមប្រក្រតី សមណព្រាហ្មណ៍ទាំងឡាយប្រាប់សេចក្ដីនៃវត្ថុនោះ ហើយបន្ទោបង់សេចក្ដីសង្ស័យ ឬឲ្យបដិបត្តិតាមសេចក្ដីពិត ។ បទដ៏សេសសូម្បីក្នុងរឿងនេះ ក៏គប្បីប្រកបដោយន័យមុននោះឯង ។

បទថា **គ្រហស្ថអ្នកអាច** សេចក្ដីថា គ្រហស្ថដែលអាចធ្វើការចិញ្ចឹមរក្សាបុត្រភរិយា ហើយគ្រប់គ្រងផ្ទះ ។ បទថា **បណ្ឌិតោ** គឺជាអ្នកឆ្លាត ក្នុងទីនមស្ការទិសទាំងឡាយ ។ បទថា **សណ្ហោ** គឺជាអ្នកល្អិតល្អន់ ដោយ

ការឃើញសេចក្ដីដែលសុខុម ឬដោយពោលវាចាដ៏ពិរោះ ។ បទថា **បដិភាណវា** គឺជាអ្នកមានបញ្ញាក្នុងទីនមស្ការទិសទាំង-ឡាយ ។ បទថា **ឱនលំទោន** គឺប្រព្រឹត្តបន្ទាប ។ បទថា **មិនរឹងត្អឹង** គឺវៀចាកការចចេស ។

បទថា **មានសេចក្ដីព្យាយាម** គឺដល់ព្រមដោយសេចក្ដីប្រឹងប្រែង និងសេចក្ដីព្យាយា-ម ។ បទថា មិនខ្ជិលច្រអូស សេចក្ដីថាប្រាសចាកសេចក្ដីខ្ជិលច្រអូស ។ បទថា **មានការប្រព្រឹត្តមិនដាច់ក្រសែ** គឺមានការប្រព្រឹត្តមិនដាច់ ដោយអំណាចធ្វើជាប់តគ្នា ។

បទថា **មេធាវី** គឺប្រកបដោយបញ្ញាដែលធ្វើឲ្យកើតឋានៈ ។

បទថា **ជាអ្នកសង្គ្រោះ** គឺធ្វើការសង្គ្រោះដោយសង្គហវត្ថុ ៤ ។ បទថា **ធ្វើឲ្យជាមិត្ត** គឺស្វែងរកមិត្ត ។ បទថា **ជាអ្នកដឹងពាក្យ** គឺដឹងពាក្យដែលបុព្វការីពោល ។ អធិប្បាយថា ក្នុងវេលាទៅផ្ទះ សំឡាញ់រលឹកដល់ពាក្យនិយាយដែលបុព្វការីនិយាយថា ពួកលោកចូរឲ្យសំពត់ជួត ចូរឲ្យសំពត់សាដកដល់សំឡាញ់របស់យើង ចូរឲ្យអាហារ និងតំលៃឈ្នួលដល់យើងទាំងឡាយ កាលគេមកផ្ទះរបស់ខ្លួន ជាអ្នកធ្វើតបត្រឹមតែប៉ុ-ណ្ណោះ ឬក្រៃលែងជាងនោះ ។ម្យ៉ាងទៀត

ដឹងពាក្យនិយាយរបស់សំឡាញ់នោះ សូម្បីចាពាក្យនិយាយដែលប្រព្រឹត្តតាមគ្នាតៗគ្នាមក មិនអាចនឹងទទួលបាន ដោយសេចក្តីខ្មាស់សំឡាញ់អ្នកមក ដោយគិតថា យើងនឹងទៅផ្ទះរបស់សំឡាញ់ ហើយនឹងកាន់យកវត្ថុនេះ ដូច្នេះ គេមកដោយប្រយោជន៍យ៉ាងណា ញុំាំងប្រយោជន៍យ៉ាងនោះឲ្យសម្រេច ឈ្មោះថាដឹងពាក្យនិយាយណេ ។

សូម្បីត្រួតត្រាមើលហើយ ឲ្យវត្ថុដែលសំឡាញ់ខ្វះខាត ក៏ឈ្មោះថា ជាអ្នកដឹងពាក្យនិយាយដូចគ្នា ។

បទថា **ជាអ្នកណែនាំ** សេចក្តីថា កាលនឹងចង្អុលបង្ហាញសេចក្តីនោះៗ ជាអ្នកណែនាំដោយបញ្ញា ។ បង្ហាញហេតុច្រើនយ៉ាងណែនាំ ឈ្មោះថា **ជាអ្នកណែនាំតាមហេតុផល** ។ ណែនាំរឿយៗ ឈ្មោះថា **តាមណែនាំ** ។ បទថា **តត្ថ តត្ថ** សេចក្តីថា ក្នុងបុគ្គលនោះៗ ។ បទថា **ដូចជារថមានប្រែកទប់ ស្ទុះទៅហើយ** សេចក្តីថា កាលការសង្គ្រោះទាំងនេះនៅមានដោយពិត លោកនៅប្រព្រឹត្តទៅបាន កាលមិនមានលោកក៏ប្រព្រឹត្តទៅមិនបាន ដូចប្រែកទប់នៅមាន រថរមែងស្ទុះទៅបាន កាលប្រែកទប់មិនមាន រថក៏ស្ទុះទៅមិនបាន ដូច្នោះ

ព្រោះដូច្នោះ លោកទើបពោលថា ការសង្គ្រោះទាំងនេះឯងក្នុងលោក ដូចប្រែកទប់រថ ស្ទុះទៅហើយ ដូច្នោះ ។ បទថា **មាតាមិនបានទទួលការរាប់អានបូជា ព្រោះហេតុនៃបុត្រ** សេចក្ដីថា ប្រសិនបើថា មាតាមិនគប្បីធ្វើការសង្គ្រោះទាំងនេះដល់បុត្រ មាតាមិនគប្បីបានការរាប់អាន ឬការបូជាព្រោះហេតុនៃបុត្រ ។ បទថា **សង្គហា ឯតេ** ជាបឋមាវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ។ ឬបាឋៈថា **សង្គហេ ឯតេ** ។ បទថា **សម្មបេក្ខន្តិ** កាត់បទជា **សម្មា បេក្ខន្តិ** ។ បទថា **បសំសា ច ភវន្តិ** ប្រែថា គួរបានទទួលការសរសើរ ។

# សិង្គាលកមាណមដល់នូវត្រៃសរណគមន៍

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សិង្គាលកគហបតីបុត្រ បានក្រាបបង្គំទូលព្រះមានព្រភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ ឬដូចជាបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេទ្រោលប្រទីប ក្នុងទីងងឹត ដោយគិតថា មនុស្សអ្នក

មានចក្ខុទាំងឡាយ រមែងឃើញនូវរូបទាំង-ឡាយ ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះ-ភាគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាសរណៈ ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិតចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ ។

ដោយប្រការដូច្នេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតីបុត្រ អ្នកចូរនមស្ការទិស ដែលបិតារបស់អ្នកពោលសំដៅដល់ហើយទ្រង់សម្តែងទិស ៦ ទាំងនេះថា ប្រសិនបើថា អ្នកធ្វើតាមពាក្យបិតា អ្នកចូរនមស្ការទិសទាំងនេះ ទ្រង់តាំងពាក្យសួរ

ដល់សិង្គាលកៈ ញ៉ាំងទេសនាឲ្យដល់ទីបំផុតហើយ ស្ដេចចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ សូម្បីសិង្គាលកៈ ក៏បានតាំងនៅក្នុងសរណៈទាំងឡាយ ហើយធ្វើទ្រព្យ ៤០ កោដិ ទុកក្នុងព្រះពុទ្ធសាសនា ធ្វើកម្មដែលជាបុណ្យ បានជាអ្នកមានសួគ៌ជាទីទៅក្នុងខាងមុខ ។ ក៏ក្នុងសូត្រនេះឈ្មោះថា កម្មណាដែលគ្រហស្ថគួរធ្វើយ៉ាងណាមួយ កម្មនោះ ដែលព្រះមានព្រះភាគមិនបានត្រាស់ទុក រមែងមានមាន ព្រះសូត្រនេះ ឈ្មោះថា **គិហិវិន័យ** ព្រោះដូច្នោះកាលស្ដាប់ព្រះសូត្រនេះហើយ បដិបត្តិតាមដែលបានទូន្មានទុក សេចក្ដីចម្រើនប៉ុណ្ណោះ

រមែងជាការប្រាថ្នាបាន មិនមានសេចក្ដីសាបសូន្យ ដូច្នេះ ។

" សិង្គាលកសូត្រ ចប់ "

## **កំណាព្យញៀន**

ញៀនក្នុងលោកិយ៍ ពុំអាចដើម្បី
ស្រដីពណ៌នា ញៀនជក់បារី
ញៀនជាប់សុីស្លា ញៀនផឹកសុរា
ញៀនជក់អាភៀន ។

ញៀនល្បែងសុីសង ញៀនក្រែកន្លង
ញៀនខំសូធ្យរៀន ញៀនដើរលេងយប់
តាមច្រកតាមកៀន មួយយ៉ាងហៅញៀន
ជក់មើលមហោស្រព ។

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

ញៀនលេងចត្រង្គ　ញៀនតែងរូបអង្គ
ញៀនលាបទឹកអប់　ញៀនជក់កញ្ឆា
និងញៀនគ្រប់យ៉ាង　ពណ៌នាពុំចប់
សុទ្ធតែហៅញៀន ។

ញៀនអស់ទាំងនេះ　មានញៀនខ្លះចេះ
បំពេញការរៀន　ឲ្យមានចំណេះ
វិជ្ជារបៀន　បែបនេះហៅញៀន
បំពេញប្រយោជន៍ ។

ញៀនធ្វើការងារ　ធ្វើស្រែចំការ
មិនឲ្យខ្វះហោច　នេះត្រូវញៀនចុះ
ព្រោះមានប្រយោជន៍　បើមានការហោច
កុំបីញៀនឡើយ ។

(និពន្ធដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ**)

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

# កំណាព្យអបាយមុខ

អបាយមុខជង្រុកហិន
សង្កិនឲ្យក្តៅដួងហឫទ័យ

ច្រើននាំអ្នកលេងឲ្យសន្ធៃ
យប់ថ្ងៃដេកព្រួយនឹកស្តាយក្រោយ ។

កំពុងប្រព្រឹត្តងងឹតឈឺង
លុះដល់រំពឹងឃើញញឹកញយ

ទើបបានយល់ច្បាស់ថាខ្លួនឆ្កោយ
ជួនក៏បណ្តោយដេញជើងទៀត ។

ដេញជើងត្រាតែឃើញលិចលង់
រឹតតែលង់ទ្រូងចង្អៀត

អ្នកខ្លះម្ល៉ឹងហើយនៅតែឆ្លៀត
អង្រៀតនឹងស្លាប់ទើបថយក្រោយ ។

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

ទំរាំភ្ញាក់ខ្លួនជួនអស់ទ្រព្យ
ជួនកាលធ្លាក់ជាប់ដល់រូបខ្សោយ

កើតរោគឈឺចាប់ស្លាប់បណ្ដោយ
គួរឲ្យព្រឺខ្លាចអបាយមុខ ។

ហេតុនោះយុវនៃយុវតី
នាងអ្នកប្រុសស្រីគួរខ្លាចទុក្ខ

ឲ្យហើយពីក្មេងទាន់មានសុខ
ត្រូវខំសម្រុកប្រឹងរៀនសូត្រ ។

នាងអ្នកចូររៀនកុំធុញទ្រាន់
ទាន់វ័យនៅក្មេងត្រូវខំស្រូត

ស្រូតរៀនឲ្យទាល់តែរហូត
បានដល់កោះត្រើយសឹមសម្រាក ។

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

វិទ្យាជាទ្រព្យដ៏ចម្បង

កន្លងលើសលែងឥតទ្រព្យសាក

ជាទ្រព្យស្រាលផងមិនលំបាក

វេចជាបង្វេចស្ពាយពុនរែក ។

ទៅមកយកជាប់ទៅជាមួយ

វិទ្យាអាចជួយឃើញទាន់ភ្នែក

ចង់បានអ្វីៗវិទ្យាស្រែក

ហៅទ្រព្យប្លែកៗឲ្យមូលមក ។

(និពន្ធដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ**)

# កំណាព្យការសេពគប់

គប់ពាលរែងពាលទៅរកខុស

គប់ប្រាជ្ញប្រុសរែងបានត្រូវ

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

គប់មិត្តអបល័ក្ខណ៍រែងអាស្រូវ
ខុសត្រូវកើតពីការសេពគប់ ។

គួរជ្រើសរើសរកជនប្រុសស្រី
តើមានធម៌អ្វីជាប្រភព

បើឃើញច្បាស់ហើយគួរសេពគប់
ឬត្រូវតែឈប់កុំរវល់ ។

បើតាមឱវាទព្រះសម្ពុទ្ធ
វិសុទ្ធទ្រង់ធម៌និរមល

គួរជ្រាបថាបើឃើញបុគ្គល
យល់ខុសពុំគួរសេពគប់ឡើយ ។

សូវនៅម្នាក់ឯងប្រសើរជាង
គួរជៀសគួរវាងជនតោះតើយ

ដោយសាមណេរ **មនោរថ យ៉ុន តារា**

# មិនប្រកាន់តាមធម៌ជាកោះត្រើយ
# ព្រងើយដោយយល់ថាខ្លួនត្រូវ ។

(និពន្ធដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ**)

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

**នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការងារធម្មទាន**

- ឧបាសក ស្វាយ ហ៊ាង និង ឧបាសិកា ទំ យ៉ម ព្រមទាំងកូនចៅ
- ឧបាសិកា ពុំ សុគន្ធារី និង កូនចៅ
- ឧបាសក-ឧបាសិកា ហៃ-នី និងកូនៗ ខីណា-ខេមា

## ឈ្មោះសប្បុរសជនចូលរួមបោះពុម្ពសៀវភៅ

យុវតី បូ ចន្ទវតី......................................................៥០០០០៛

ឧបាសិកា សោម សុខែម+លោកឪពុកសោមអ្នកម្ដាយសុខុន..១០$

លោកតាឈឹម និងភរិយាបុត្រនិងសប្បុរស(ភូមិបុណ្ណា)៣៦០០០៛

អ៊ុក ធុច និង សេង ម៉ាក់លី.....................................៣៣០០០៛

ភិក្ខុ សូត្រ ហួរ ចៅអធិការវត្តទួលគោកស្វាយ..............៣០០០០៛

ភិក្ខុ ឃោសធម្ម ឃឿន សុខឃី(វត្តមហាខេត្តរនៃ).........៣០០០០៛

ភិក្ខុ សមណៈសំវរោ ជ្រែង កុសល(សមណៈសិស្សវត្តប្រាសាទនាងខ្មៅ)..........................................................................៣០០០០៛

ភិក្ខុ មេដ្ឋោ សាត សំអុល(វត្តមហាខេត្តរនៃ)..............៣០០០០៛

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

លោកម្ចាស់ ផេង ភារ៉ា(វត្តមហាខេត្តរ៉ែន)...................៣០០០០៛

សាមណេរ តុប(វត្តមហាខេត្តរ៉ែន)............................៣០០០០៛

លោកយាយ សៅ(ភូមិអំបិស)................................៣០០០០៛

លោកយាយ ភី ព្រមទាំងបុត្រ(ភូមិអំបិស)................៣០០០០៛

ឧ.ស ប៊ូ ចន្ថា ឧ.សិ ឃុត សំអឿន............................៣០០០០៛

ភិក្ខុ បដ្ឋោត្តោ ថន វណ្ណី .......................................៦០០០០៛

សាមណេរ សល់ សឹង..........................................៣០០០០៛

ទេព វិចិត្រ.ស៊ី សឿង.ឡូន ស្រីល័ក្ខ.ឡូន ស្រីឡែន.ឡូន ស៊ីនួន.ឡូន ឡាំហេង.ទេព សាឡុន.ទេព សារិទ្ធ..........២៤០០០៛

តិច សុចាន់......................................................២៣០០០៛

ឧ.ស យ៉ាន សារិនយ៉ា និងឧ.សិ អ៊ុំ សារ៉េន.................២០០០០៛

ឧបាសិកា ឃុន វ៉ៃ(វេយ្យាវច្ចវត្តអង្គពណ្ណរាយណ៍)........២០០០០៛

ប៊ុន ខា និង ឈួន ង៉ោ..........................................១៥០០០៛

សុខ នី. ស៊ីណូន. នី ផានី.......................................១៥០០០៛

លោក ខាំ ខឿន អ្នកស្រី សៅ ចន្ធូ និងបុត្រ................១៥០០០៛

លោកយាយ សួន អេម(ភូមិឆ្នាពួន).........................១៥០០០៛

លោក សយ សន និង សាប់ ម៉នព្រមទាំងបុត្រ...........១២៥០០៛

ឧបាសក យ៉ាង សយ............................................១៣០០០៛

គុណម្ចាស់ ឡូ សុភ័ណ្ឌ.........................................១២០០០៛

លោកយាយ វ៉ង លី លោកយាយ ក្រឹម និងបុត្រ..........១១០០០៛

ភិក្ខុ ពុទ្ធធិកោ ណុប ប៊ុត........................................១០០០០៛

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

ស៊ី ណាតតុលា ព្រមទាំងបុត្រ.................................១0000៛

ម៉េ រ៉េត......................................................១0000៛

សុខ ថន.......................................................១0000៛

យ៉ន សុភី.....................................................១0000៛

អ៊ុន ស៊ីម.....................................................១0000៛

យ៉ាន ឆៃលាភ.................................................១0000៛

រី សារ៉ាត់.....................................................១0000៛

សុភាព ស្រីរដ្ឋា................................................១0000៛

ហេង សុពណ៌.................................................១0000៛

ស្រេង ឈាង..................................................១0000៛

អ៊ុន រឹម ព្រមទាំងកូនចៅ........................................១0000៛

លោក សន សំអាត និង ភរិយា...............................១0000៛

ណុប ឆេងទី...................................................១0000៛

រិន សោភ័ន(ភូមិហា)..........................................១0000៛

លោកយាយ យុត ព្រមទាំងចៅ(ភូមិធ្នាពួន)..............១0000៛

សាមណេរ សុជាតោ ឆែម លីដា(វត្តមហាខេត្តរ៉ៃ).......១0000៛

លោកស្រី ឆែម សុខែម និង រ៉ែន វល(ភូមិធ្នាពួន).........១0000៛

សុន សន......................................................១0000៛

អ៊ុន មៃ.......................................................១0000៛

កញ្ញា ធី វណ្ណី(ភូមិប្រជុំអង្គ).................................១0000៛

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

ឈ្មោះពុទ្ធបរិស័ទចូលរួម៩០០០រៀល

ភិក្ខុ សុត សន,សុង ឡូ(ភូមិស្រុកធំ),ស៊ីម វណ្ណធឿន(ភូមិស្រុកធំ),សំ ហៀង,យាយ ប៊ុត(ភូមិអំបិស),ម៉ុន ណន ព្រមទាំងបុត្រ,សយ លី,អ៊ឹម សុត និងកូនចៅ,អ៊ី សុខនី និងកូន,វន ឡៃ និងកូន,

ឈ្មោះពុទ្ធបរិស័ទចូលរួម៦០០០រៀល

ភិក្ខុ ផល សុភ័ណ,សាមណេរ រឿន រត្ន,ជាងគំនូរ ហ៊ន់ វិចិត្រ និងយី សុឃឿន,ឌី ស្រ៊ី,កង់នៅ ឌី,សំ ហឿន និង កាន់ សារិកា,សំ ហៀន និងចៅកាន់ សកល,គរ ច្រិប,លោកគ្រូ កាន់ សារិកានិងសំ ហឿន, យាយ យុត(ឆ្នាពួន),លោកយាយ អ៊ុំ និងកូន(ឆ្នាពួន),យាយ ទេស(ភូមិពោស្នាត),លោកយាយ ផលី(ភូមិស្រុកធំ),លោកយាយ ទ្រី ហុក,លោកគ្រូ វុទ្ធី និងភរិយាបុត្រ,មឿន ចាន់សុវណ្ណា,ស៊ីម ឌីណា,ខន សំនៀង,សារី និង សំអាត,ភោគ ស្រីលក្ខណ៍ និង សំ ស្រីណយ,ឱ.សយ៉ែម យ៉ាន.ឱ.សិគល់ សារឿន, យាយ នឹងស្រី មុំ.តាប៊ឹម យ៉ង់,ម៉ែន ចំរើន និង ស្រីមុំ,ផាន ដុស ព្រមទាំងបុត្រ,តា គង់ ម៉ាក់.យាយ វ៉ាន់ ប៊ុត.ម៉ាក់ នី.ប៉េង ផូ,ឃឿន ណុន ព្រមទាំង បុត្រ,រ៉ា សុខនាង.សិលា.ផារិន,ពឿង ប៉ាក់.ស៊ី ពៅ,យាយ នេត

មៀច.យាយ អ៊ុល សំ,គាង ចាន់ឌី ព្រនទាំងបុត្រ,នៅ ម៉ន.ស៊ីមន.យុត យាយខឹម,សុងលី ចិន្តា (ភូមិធ្នាពួន),តាសុំ យាយផុល,ឧ.ស អ៊ុន អ៊ុល,ផានិត និង មុំ,វន ចន្ទី និង ភរិយា ព្រមទាំងបុត្រ,ចំរើន ចាន់ឈឿន និង ភរិយា,រស់ សុផល.ឯម សារឿន ព្រមទាំងបុត្រ.នឹម ណុំ.យ៉ែម ឡេង ព្រមទាំងបុត្រ,ហ៊ីន ខាន់ ព្រមទាំងបុត្រ,លោក សូ ចាន់ថន អ្នកស្រី សុត រស់ ព្រមទាំងបុត្រ,លោក ចៀម ចុន និង អ្នកស្រី សន រិត,ប៉ែន សារឿន(ព្រៃកហូរ),ជៀម ឌី និង កូន សុកជិនខោង,ភួង សេន,ខុន សុខចុល,ភួង សុំ.ដុះ ស៊ុន.ជៀង នៅ,ពូក.ខែម.គុង.ម៉ាលី ចៅ,ផាត ផល្លី ព្រមទាំងបុត្រឌីណា,លោក តាយ៉ាន ខាន់ និងយាយ ផូ,ជិន ច្រឹម,ម៉ៃ យឿន ព្រមទាំងបុត្រ,យុន សំបុក ពកថាច,

ឈ្មោះពុទ្ធបរិស័ទចូលរួម៥០០០រៀល

ជា ម៉ាហោ និងភរិយា,អ៊ុល អូន,ខាន់ សំអាត,យាប់ សំអាង,ឧ.ស នៅ នន់ និង ឧ.សិ ហែម នឹម,ប៉ាង ប៊ុនស៊ិន,កែ រ៉ាត និងកូន,អុន អែម និង ផុន សាមឿន,នួន យ៉ាន,អាង សូត,យាយ វន និងកូនចៅ,ឧ.ស ម៉ែន សារី,យាយ យួន, ផាន ទឹម និងកូនចៅ,ហ៊ីន យ៉ាត និងកូនចៅ,អាចារ្យ សេន(គោកស្នាយ),ប្រាំង សុភ័ណ្ឌ និង អេម សុខលី,

ឈ្មោះពុទ្ធបរិស័ទចូលរួម១$ ឬ ៤០០០៛

*ដោយសាមណេរ* **មនោរថ យ៉ូន តារា**

ជិន ស្រីមុំ(សាលាសុវណ្ណារ៉ាព្រៃកហូរ),ផុន សារឿន ព្រមទាំងក្មួយ, រឿន រ៉ាវី,រឿន ចន្ទី,ភា ផារី,ផុន កឿន.អ្នកស្រី ទុយ សឿង,ភឹម អាត់ ,គៀង នី.ផល ផេន ព្រមទាំងកូនចៅ,សុផល សុភា,ពៅ សុខកប ,ឧ.ស វន ឈន,យ៉ែម ទឿន,

ឈ្មោះពុទ្ធបរិស័ទចូលរួម៣០០០រៀល

កែវ យន,កែវ សុខា,សេន យឺន,ញៀន សំអាត,ឧ.ស សៅ ឡុញ និងឧ.សិ មាស ប៉ុន,ជីន ចុន,ថន សុខឡូត,នុជ យ៉ន,នៅ កាន,ឱន យ៉ែម,លី សុវណ្ណ.ឈួ ចាន់,ថាន ទូច,ភោគ ផានីតា,ហង្ស សុផា, សុវុន រ៉ាយុទ្ធ,យាយ ង៉ូត(ស្រុកធំ),យាយ ង៉ែត យាយ លុន (ក្រសាំង),យាយ អាន(ភូមិត្រាំស្បូវ),យាយ សំ(ក្រសាំង) ,លោកអាចារ្យ អោម អាន(វត្តស្រែព្រៃ),សទ្ធារបស់ក្មេងៗ,សៀន សុខានិងបុត្រ,ហ៊ិច លិននិងបុត្រ,ហេង ចេង,ឧ.សិ ឈុំ ផល្លា,សុខ ផល ព្រមទាំងស្វាមីនិងបុត្រ,រ៉ន ធីតារ័ត្ន,ពៅ ផា,កុមារ៉ានិងកុមារី អោក សុវណ្ណារ៉ា និង អោកសុវណ្ណារី,យាយ អ៊ុណ និងកូនចៅ,អាត ទូច និងកូនចៅ,ឧ.សិ អួន និងកូនចៅ,យុន ឡាង,អំ វណ្ណី និង អ៊ុំ ធូ,សន ស្រីមុំ,តា ប៊ុន យាយ យី និងបុត្រ,សូណា,ភី ភន និង ទូច សុខខែម,ទិត្យ ហៀង និង រ័ត្ន សុជាតិ,ថា វុទ្ធី,លឹម ណម,អោក វណ្ណា និង ចន ចាន់ផានី,យាយ កង់,ថា ដាណោ,សឿន លីណា និង ផៃ សុវណ្ណា,ចាន់ថា សុវណ្ណាដារ៉ា,ថា ភារុំ,ចាន់ភសុធា,ណែម

លាប,ណែម លន,បួន សម្កស្ស,ឃួន ឧ.សិ មើ,ភិន ស្រី,ញែម សារី,សូត្រ កលិកា,ធឿន អុន,គាំ រីម,សែម ចក់,ហៀង គន្ធា,ពាង បុប្ផា,សុខ ទូច,លោក ហោ នៅ,យឹម ស្រីពេជ្រ ព្រមទាំងបុត្រ ,សម្បត្តិ,ពេជ្យ ពឿង,យាយ ព្រិច,អាន យ៉ាន់,ពុំ ទួន,ឆាយ យាន,អ៊ូ ណាំ,វន ចន្នី,មាន សាម៉ន និងភរិយា,នួន ផូ,អាត ហោ,មាន សាម៉េន និងស្វាមី,ផុន ចាន់ណូ.លោក ស៊ឹម គង់,សន សុខុម.រឿន កំសាន្ត ព្រមទាំងបុត្រ,រុំ សុភាព,រិត អាន(ពោធ៍ត្នាត),សុវណ្ណ ឆៃយ៉ា,ជី ខន,ផៃ វីរៈ,ផល្លា ផាន,កុមារី ចន្ទី និមល,យ៉ែម លាភ, មែម ស្រីអូន,មាន រំដួល និងស្វាមី,យ៉ែម ទូច,សុវណ្ណ ធរី,សុវណ្ណ ស្រីនិច,រឿន នៅ,អ្នកស្រី រឿន រិន និង អ្នកស្រី អ៊ុន រ៉ាន់,កុមារី ចន្ទី ណារី,រុន សារិន និង ចាន់វណ្ណនីដា,វ៉េង កុយ និង ប៊ី ដា,ស៊ែម ណម ព្រមទាំងបុត្រ.យាយ ណាន,អ្នកស្រី ជៀម សាវ,ជៀម ថន និង ភរិយា,ជិន ស៊ីថា និង ភរិយា,វិត សុផល,ថន ជារី.ថន ជារ៉ា .សួន សុខគង់,សុត សុខ.ចែម ជឿក,សូត្រ សុកខឿន,វិត ផល,ថុល ជា,ភួង ប៉ាក់,ញ៉ាម សាមិត្ត.ហ៊ាន គឹម,ស៊ុក ទី.ជា ជូរ,តាំង គឹមលី .សេង ពៅ,ស វ៉ន,សម្បត្តិ សំបូរ,នៅ បូរី.រិទ្ធ សុខហេង,រិទ្ធ ស្រីពៅ ព្រមទាំងបុត្រ,ញ៉ាញ់ សឿង,ទ្រី យ៉ាង,ខុម ស្រីឡឹង,ពឿន ស៊ីម,ផៃ សុខលី ព្រមទាំងបុត្រ,សារ៉ូ ចាន់ថា,មិន ផល្លី ព្រមទាំងបុត្រ,ឈឿន ស្រីម៉ៅ,ប្រុស ស្រីឡេង,កង រ៉េ ព្រមទាំងបុត្រ,ថោង សំអាត,ឡាំង ចាន់ថន,យាយ ណុន,សម សៅ.ដួង សំណាង,ឧ.ស នូវ ផៃ.ឧ.សិ ពឿង លឹម,សុំ ផុល, នឿន សន់,ហេង លាងសេង,ស៊ុន ប៉ៃ.ជីក

ភាព,តែ ហាំងគី.ទា អៀងឡេង.តែ គៀងអ៊ុយ.តែ គៀងហ៊ាង.តែ គៀងជូ.តែ គៀងណៃ,ឈឿន ស្រីនិត.ឈឿន ស្រីណៃក ស្រស់ ស្រីពី.ម៉ារ៉ា រិទ្ធសុទ្ធានិជ,យាង យឿន និង ភរិយា ព្រមទាំងបុត្រ,បូ នារីរតនៈ,ផាត ចាន់សុខ,បិច រ៉េម,យាយ ណម,ប៊ុន វ៉ាង,ប៉ូច លី .អ៊ុយ សិត.ប៉ូច ងន,ឧ.ស ប៉ែន គុន,រិន សារ៉េន,ឈុំ ថុន,ប៉ែន ណាត,ទុយ វ៉ាន់,រិន ខេន,កញ្ញា ពន់ ច័ន្ទខេមរិន,សំ ស៊ុម,កឹម រ៉ុ, កញ្ញា ពេញ វណ្ណី,លោក ធី.នាង សុស,ផន ងាន់,កឹម ម៉ាច(ភូមិ ពៅព្រៃ),ឧ.សិ សួល លន(ភូមិកណ្តោក),ឈៀង ស៊ន,យី យ៉ាវ ចំរើន,ផាត ហ៊ុច,ចំរើន សុខុម,គឹម ស៊ន,ពឿង រី,ក្លូង យី,ឧ.សិ ណយ សុខុម.ឧ.ស ម៉ុន,ឈីន គឹមឈឿន និងភរិយា.សឿន សុខ អេង និងបុត្រ,សំរិត រៀម,យុវជន ណម ពេជ្រ,ម៉ែន ចំរើន,ភ័ស វន, កុំ ឡៃស៊ឹម,បួន ស៊ីណា,សេង សយ, សៀង វង(ព្រៃករទាំង),ផល្លី សុផា,ហែម ផាន់(បឹងទំពុន),កន សាន,

ឈ្មោះពុទ្ធបរិស័ទចូលរួម២០០០រៀល

កឿន ស្រីតុន,ឌុក ឌី,ឡៃ ដា,

ឈ្មោះពុទ្ធបរិស័ទចូលរួម១៥០០រៀល

កុមារី រិន ឡាយ,

ឈ្មោះពុទ្ធបរិស័ទចូលរួម១០០០រៀល

*ដោយសាមណេរ* **មនោរថ យ៉ុន តារា**

យាយ ជួក,ម៉ាក់ ប៊ុត,

ឈ្មោះពុទ្ធបរិស័ទចូលរួមដែលមិនបានដាក់ចំនួនថវិកា

យែម យ៉ង់,ឡាក់ ប៉ង់,ហេង លន់,ស្រីពៅនិងវិសេស,ប៉ូច ច័ន្ទតារ៉ា និងមី សារានី,តឿន ស្រីនាង,ម៉ុន សុខសី,ឈន ឆន,ប៉ូច សារឿង ,បឹន ចាន់ថន,ហ៊ីង សុខចំរើន និងវាសនា ស្រីនិច,



**សាមណេរ មនោរថ យ៉ុន តារា**

មិត្តេ ភជស្សុ កល្យាណេ　　បដ្តញូ សយនាសនំ
វិវិត្តំ អប្បនិគ្ឃោសំ　　មត្តញ្ញូ ហោហិ ភោជនំ។

អ្នកចូរគប់រក នូវកល្យាណមិត្ត និងទីដេក ទីអង្គុយ
ដែលស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង
ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។